ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រមជំនាញតែកម្ម

នៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់គិលានុបដ្ឋាក

២០១៩

ឧបត្ថម្ភដោយ





អនុវត្តដោយ៖ giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH



អារម្ភកថា

ក្របខ័ណ្ឌនិយ័តកម្មនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់គណៈគិលានុបដ្ឋាកកម្ពុជា ត្រូវបានរៀបចំឡើងដើម្បីចូលរួមការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងអ្នកវិជ្ជាជីវៈសុខាភិបាល ដើម្បីការពារសុខភាព សុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងធានាអ្នកប្រកបវិជ្ជជីវៈសុខាភិបាលទាំងអស់មានគុណវុឌ្ឍិ សមត្ថភាព និងសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

គោលបំណងនៃក្របខ័ណ្ឌនិយ័តកម្មនេះ គឺផ្តល់ការណែនាំដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល សំរាប់បំពេញចំនួនពិន្ទុដែលបានមកពីការបណ្តុះបណ្តាលបន្តសំរាប់ស្នើសុំការបន្តអជ្ញាប័ណ្ណ ក៏ដូចជាអង្គភាព រឺដៃគូផ្តល់ការបណ្តុះបណ្តាលបន្តសំរាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្នុងការរៀបចំ និងស្នើសុំពិន្ទុសំរាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ពីគណៈគិលានុបដ្ឋាកកម្ពុជា។

ក្របខ័ណ្ឌនិយ័តកម្មនេះគឺជាលទ្ធផលពីការខិតខំប្រឹងប្រែងរបស់ក្រុមការងារបច្ចេកទេស របស់គណៈគិលានុបដ្ឋាកកម្ពុជា ក្រោមការដឹកនាំ និងសម្របសម្រួលរបស់គណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាល ក្រោមការឧបត្ថម្ភគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ GIZ និងក្រុមហ៊ុន B.Braun។

គណៈគិលានុបដ្ឋាកកម្ពុជាសង្ឃឹម និងជឿជាក់ថាក្របខ័ណ្ឌនិយ័តកម្មនេះ និងមានសារៈប្រយោជន៍ចំពោះអ្នកប្រកបវិជ្ជាជីវៈថែទាំ អង្គភាព រឺដៃគូផ្តល់ការបណ្តុះបណ្តាលបន្ត សំរាប់វិជ្ជាជីវៈថែទាំទាំងអស់ និងភាគីពាក់ព័ន្ធទាំងអស់ដើម្បីចូលរួមគាំទ្រការអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ក្នុងការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៩

ជ. ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ

ប្រធាន

អនុបណ្ឌិត អ៊ុន សាន

សេចក្តីថ្លែងអំណរគុណ

តាំងនាមអោយគណៈគិលានុបដ្ឋាកកម្ពុជា យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលបានគាំទ្រ និងបង្កលក្ខណៈងាយស្រួលក្នុងដំណើរការរៀបចំក្របខ័ណ្ឌនិយ័តកម្មនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់គណៈគិលានុបដ្ឋាកកម្ពុជានិងសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យ ជា គ្រុយ** ប្រធានគណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាល និងជារដ្ឋលេខាធិការក្រសួងសុខាភិបាលក្នុងការដឹកនាំនិងសម្របសម្រួលការងារបច្ចេកទេសសំរាប់ការរៀបចំឯកសារនេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ដល់ក្រុមការងារបច្ចេកទេសគណៈគិលានុបដ្ឋាកកម្ពុជាទាំងអស់ដែលបានចូលរួមក្នុងការរៀបចំក្របខ័ណ្ឌនិយ័តកម្ម នៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះឡើង ជាពិសេសកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ GIZ ក្រុមហ៊ុន B.Braun និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត។

គណៈគិលានុបដ្ឋាកកម្ពុជាសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ដែលមានរាយនាមដូចខាងក្រោម៖

ក្រុមការងារបច្ចេកទេស ពិនិត្យកែសម្រួល និងផ្តល់ប្រឹក្សា

១. លោក អ៊ុនសាន	ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ
២. លោកមាស សារិទ្ធិ	អនុប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ
៣. លោកថៃ សុវណ្ណារ៉ា	អនុប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ
៤.លោកស្រី ម៉ៅ តាន់ណារី	អគ្គហេរញ្ញិកក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ
៥.លោកហ៊ុន សេរីវឌ្ឍនា	អគ្គហេរញ្ញិករងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ
៦. លោកប្រុញ សុមិត្ត	អគ្គលេខាធិការរងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ
៧. Ms. Alyson Smith	Principal Consultant - health professions' regulation; policy and education, Alyson Smith Consulting Pty. Ltd
៨. លោកស្រី ជាង សារីម	ទីប្រឹក្សាបច្ចេកទេស GIZ
៩. កញ្ញា ឃូ គឹមលិន	ទីប្រឹក្សាបច្ចេកទេស GIZ

មាតិកា

អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

តារាងអក្សរកាត់

សេចក្តីផ្តើម ១

គណៈគិលានុបដ្ឋាកកម្ពុជា ១

តួនាទីរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកកម្ពុជា ២

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ២

ការអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងបរិបទទីកន្លែងប្រកបវិជ្ជាជីវៈ ២

ភាពចាំបាច់នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៣

អត្ថប្រយោជន៍ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៣

គោលការណ៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៤

គោលដៅការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៥

សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៥

លក្ខណៈវិនិច្ឆ័យ/តម្រូវការ និងការទទួលស្គាល់ ៦

សេចក្តីសម្រេច ស្តីពីនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ ៩

គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត ១៦

ឧបសម្ព័ន្ធ ក ៖ ផែនការសិក្សាផ្ទាល់ខ្លួន សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ២៨

ឧបសម្ព័ន្ធ ខ ៖ កំណត់ត្រា សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត ២៩

គោលការណ៍ណែនាំស្តីពីអង្គភាព ឬដៃគូផ្តល់ការសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៣១

ពាក្យស្នើសុំសម្រាប់ការអនុម័តផ្តល់ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៤៦

ពាក្យស្នើសុំទទួលស្គាល់ជាអង្គភាព ឬដៃគូបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៥០

សាលាកប័ត្រព័ត៌មាន ៥៦

តារាងអក្សរកាត់

AJCCN	គណៈកម្មាធិការសម្របសម្រួលរួមអាស៊ានលើការថែទាំ
ASEAN	សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
CCN	គណៈគិលានុបដ្ឋាកកម្ពុជា
CPD	ការអភិវឌ្ឍវិជ្ជាជីវៈជាបន្ត
GIZ	Deutsche Gesellschaft für Internationale Zusammenarbeit GmbH
HSP3	ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ នៃរាជរដ្ឋាភិបាលកម្ពុជា
ICN	ក្រុមប្រឹក្សាអន្តរជាតិនៃគិលានុបដ្ឋាក
SDGs	គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ

សេចក្តីផ្តើម

គណៈគិលានុបដ្ឋាកកម្ពុជា

គណៈគិលានុបដ្ឋាកកម្ពុជា (CCN) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៧ ក្នុងគោលបំណងដើម្បីជានាសុវត្ថិភាពសាធារណៈ ដោយចែងក្នុងប្រព័ន្ធអប់រំគិលានុបដ្ឋាក និងការបង្កើតទិសដៅយុទ្ធសាស្ត្រសម្រាប់ CCN និងការត្រួតពិនិត្យមើលការងាររបស់បុគ្គលិកជាន់ខ្ពស់របស់ CCN ។ ដោយមានកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស , គិលានុបដ្ឋាកនៃមន្ទីពេទ្យជាតិ និងសាលាបណ្តុះបណ្តាលគិលានុបដ្ឋាកតាមខេត្ត CCN មានសេចក្តីសោមនស្សរីករាយ សូមបង្ហាញនូវគោលការណ៍ណែនាំ ស្តីពីការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ត (CPD) សម្រាប់គិលានុបដ្ឋាក។ គោលការណ៍ណែនាំថ្មីនេះត្រូវបានបង្កើតឡើងដើម្បីពិព័ណ៌នាពីការរំពឹងទុករបស់ CCN លើគិលានុបដ្ឋាកដែលបានចុះបញ្ជីទាំងអស់ទាក់ទងនឹងការថែរក្សាការអភិវឌ្ឍជំនាញវិជ្ជាជីវៈជាបន្តរបស់ពួកគេ។ គិលានុបដ្ឋាកដែលបានចុះបញ្ជីផ្តល់នូវការមើលថែទាំផ្ទាល់ដល់អ្នកជម្ងឺ និង/អតិថិជនភាគច្រើនបំផុតលើសេវាសុខភាពរយៈពេល ២៤ម៉ោង។ គិលានុបដ្ឋាក មានចំនួនច្រើនជាងគេបង្អស់នៃអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលទាំងអស់ ហេតុដូច្នេះហើយបានជាមានសក្តានុពលដើម្បីរួមចំណែកលើសុខភាពប្រជាជន និងជួយថែរក្សាសុវត្ថិភាពអ្នកជម្ងឺ និងគុណភាពនៃសេវាសុខភាព។ ការបង្កើតគោលការណ៍ណែនាំស្តីពី CPD សម្រាប់គិលានុបដ្ឋាកនៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយផ្អែកលើការត្រួតពិនិត្យលើក្របខណ្ឌ និងច្បាប់ជាតិ និងអន្តរជាតិ និងអន្តរជាតិជាច្រើនដូចខាងក្រោម៖

- គោលដៅអភិវឌ្ឍដោយចេរភាព (SDGs) របស់អង្គការសហប្រជាជាតិ
- គណៈកម្មាធិការសម្របសម្រួលរួមរបស់អាស៊ាន លើគិលានុបដ្ឋាក (AJCCN) ផែនការការងារ ២០១៦ - ២០២៥
- ផែនការយុទ្ធសាស្ត្រសុខាភិបាលទី៣ ២០១៦-២០២០ (HSP3) របស់រាជរដ្ឋាភិបាលកម្ពុជា
- ផែនការអភិវឌ្ឍកម្លាំងពលកម្មសុខភាព ២០១៦-២០២០របស់ក្រសួងសុខាភិបាល
- ច្បាប់ស្តីពីការគ្រប់គ្រងការអនុវត្តផ្នែកសុខាភិបាល
- ផែនការយុទ្ធសាស្ត្រជាតិនៃក្រុមប្រឹក្សាវិជ្ជាជីវៈសុខាភិបាល ២០១៥ – ២០២០

តួនាទីរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកកម្ពុជា

CCN ការពារសុខភាព និងសុខមាលភាពរបស់ប្រជាជនកម្ពុជាតាមរយៈ៖

- ការធានាថាគិលានុបដ្ឋាកទាំងអស់បានចុះបញ្ជិកានិងបង់ថ្លៃប្រចាំឆ្នាំដើម្បីរក្សានូវការចុះបញ្ជិកានោះ
- ធានាលើការអនុវត្តស្តង់ដារវិជ្ជាជីវៈដូចជា ក្រមសីលធម៌សម្រាប់គិលានុបដ្ឋាក និយាមនៃការថែទាំអ្នកជម្ងឺ ក្របខណ្ឌនៃដំណើរការនៃការថែទាំ ពិធីការនៃការថែទាំ និងឯកសារគ្រឹះសម្រាប់គិលានុបដ្ឋាកដ៏ទៃទៀតដើម្បីលើកកម្ពស់គុណភាព និងសុវត្ថិភាពនៃការថែទាំសម្រាប់អ្នកជម្ងឺ និង/អតិថិជន
- ធានាថាគិលានុបដ្ឋាករក្សានូវសមត្ថភាព និងគាំទ្រនិយាមនៃការអនុវត្តវិជ្ជាជីវៈថែទាំអ្នកជម្ងឺ
- ការស៊ើបអង្កេតលើការតវ៉ារបស់គិលានុបដ្ឋាកទាក់ទងនឹងការអនុវត្តវិជ្ជាជីវៈ សមត្ថភាព និងសុខភាពផ្លូវចិត្ត ឬផ្លូវកាយ និងការកំណត់ការដាក់ទណ្ឌកម្មដែលសមស្រប (ការប្រព្រឹត្ត ឬសមត្ថភាពវិជ្ជាជីវៈ) ឬសកម្មភាពការពារ (ការប៉ះពាល់សុខភាពផ្លូវកាយ ឬផ្លូវចិត្ត)។

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ក្រុមប្រឹក្សាអន្តរជាតិនៃគិលានុបដ្ឋាក (ICN) កំណត់ការអភិវឌ្ឍវិជ្ជាជីវៈជាបន្ត (CPD) គឺជាដំណើរការយូរអង្វែងនៃការថែទាំ និងការលើកកម្ពស់សមត្ថភាពរបស់គិលានុបដ្ឋាក។ CPD មានសារៈសំខាន់ណាស់សម្រាប់គិលានុបដ្ឋាកដើម្បីរក្សានូវសមត្ថភាពវិជ្ជាជីវៈតាមការរក្សាបច្ចុប្បន្នភាពជាមួយនឹងការផ្លាស់ប្តូរបរិស្ថាននៃការថែទាំសុខភាពយ៉ាងឆាប់រហ័ស ដោយសារតែការកែចម្រើនជាបន្តបន្ទាប់លើចំណេះដឹង និងការអនុវត្តប្រកបដោយជាតុពិតជាក់ស្តែងបែបវិជ្ជាជីវៈ បច្ចេកវិទ្យាថ្មី និងកិច្ចអន្តរាគមន៍លើសេវាថែទាំសុខភាព។ គោលការណ៍ណែនាំស្តីពី CPD សម្រាប់គិលានុបដ្ឋាកនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ជា «ដំណើរការនៃការសិក្សាដ៏វែងឆ្ងាយក្នុងគោលបំណងបំពេញតាមតម្រូវការរបស់អ្នកជម្ងឺ និងការធ្វើអោយប្រសើរឡើងនូវលទ្ធផលផ្នែកសុខភាពតាមរយៈការកែលម្អរជាប្រព័ន្ធ និងការង្កើនការយល់ដឹង ការស្វែងយល់ និងជំនាញ និងការអភិវឌ្ឍគុណសម្បត្តិបុគ្គលដែលចាំដល់ការអនុវត្តកាតព្វកិច្ចវិជ្ជាជីវៈ ដោយរួមបញ្ចូលទាំងដំណើរការនៃការទទួលតួនាទី និងការទទួលខុសត្រូវថ្មី»។

ការអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងបរិបទនីតិវិធីប្រកបវិជ្ជាជីវៈ

ការអនុវត្តមានន័យលើគ្រប់តួនាទីទាំងអស់ មិនថាបានប្រាក់ចំណូល ឬមិនបាន នៅគ្រប់ពេលវេលា និងទីកន្លែងដែលគិលានុបដ្ឋាកទាំងឡាយអាចប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ពួកគេជាបុគ្គលអនុវត្តសេវាសុខភាពនៅក្នុងវិជ្ជាជីវៈរបស់ខ្លួន។ ការអនុវត្តក្នុងបរិបទនេះមិនត្រូវ

បានដាក់កម្រិតទៅលើការផ្តល់ការថែទាំព្យាបាលដោយផ្ទាល់នោះទេ។ ការអនុវត្តរួមបញ្ចូលទាំងការប្រើប្រាស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ ដែលមិនពាក់ព័ន្ធនឹងការព្យាបាលដោយផ្ទាល់ជាមួយអតិថិជននៅក្នុងមន្ទីពេទ្យ គ្លីនិក មណ្ឌលសុខភាព មណ្ឌលកុមារកំព្រា ការងារទាក់ទងនឹងការគ្រប់គ្រង រដ្ឋបាល ការអប់រំ សិក្សាស្រាវជ្រាវ ផ្តល់ការប្រឹក្សាយោបល់ អ្នកដែលមានតួនាទីជាអ្នកបង្កើតបទបញ្ញត្តិ និងគោលការណ៍ផ្សេងៗ និងតួនាទីផ្សេងៗទៀតដែលមានផលប៉ះពាល់លើសុវត្ថិភាព ការផ្តល់សេវាប្រកបដោយប្រសិទ្ធិភាពក្នុងជំនាញវិជ្ជាជីវៈថែទាំ។

ភាពចាំបាច់នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ស្ថិតក្នុងបរិស្ថានមួយដែលមានការផ្លាស់ប្តូរឆាប់រហ័ស បច្ចេកវិទ្យាព័ត៌មាន ការកើនឡើងនូវការរំពឹងទុក និងតម្រូវការពីសាធារណជនលើគុណភាព និងការទទួលខុសត្រូវដ៏ធំធេង យើងចាំបាច់ត្រូវការ CPD សម្រាប់អ្នកជំនាញវិជ្ជាជីវៈសុខាភិបាល ដើម្បីរក្សានូវសមត្ថភាពជំនាញរបស់ពួកគេ។ គិលានុបដ្ឋាកជួបនូវបញ្ហាប្រឈមជាច្រើនក្នុងការទទួលយកនូវវិធីសាស្ត្រថ្មីៗ លើផ្តល់ការថែទាំដែលនឹងផ្តល់នូវសេវាប្រកបដោយគុណភាព ដែលយកចិត្តទុកដាក់លើអ្នកជម្ងឺនិង/អតិថិជនយ៉ាងពិតប្រាកដ។ សកម្មភាព CPD ទាំងអស់នេះចាំបាច់ជួយសម្របសម្រួលដល់សមាសភាពនៃការចូលរួម ភាពពាក់ព័ន្ធទៅនឹងការអនុវត្តវិជ្ជាជីវៈពេលបច្ចុប្បន្ន និងការធ្វើសមាហរណកម្មលើចំណេះដឹងថ្មីទៅក្នុងការអនុវត្តជាក់ស្តែងដោយផ្អែកលើភស្តុតាងថ្មីៗ។

អត្ថប្រយោជន៍ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

CNN កត់សម្គាល់ឃើញថា CPD ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយគិលានុបដ្ឋាកអោយទទួលយកនូវកម្រិតចំណេះដឹងជំនាញ និងអកប្បកិរិយាទាន់សម័យ (ទាន់បច្ចុប្បន្នភាព) និងថ្មីដែលមិនត្រឹមតែបន្ថែមនូវអត្ថប្រយោជន៍ដែលអាចវាស់វែងបានលើការអនុវត្តវិជ្ជាជីវៈ ថែមទាំងជួយលើកកម្ពស់ និងពង្រឹងបន្ថែមនូវសុច្ចរិតភាពវិជ្ជាជីវៈដើម្បីជាប្រយោជន៍ដល់អ្នកជម្ងឺ ឬអតិថិជន។ ចំណេះដឹង ពត៌មាន និងជំនាញដែលទទួលបានរបស់គិលានុបដ្ឋាក ក្នុងនាមជាសិស្ស និង/ឬ បុគ្គលិករាជការ នឹងប្រើប្រាស់លែងបានតទៅទៀតក្នុងខណៈពេលណាមួយនោះ។ ការទទួលយកដំណេះដឹង និងជំនាញថ្មីៗសម្រាប់ជំនាញថែទាំគឺតែងតែមានជានិច្ច។ ដើម្បីការពារសាធារណជនដោយធានាការលើកកម្ពស់សុខភាពសង្គម គិលានុបដ្ឋាកត្រូវមានការប្តេជ្ញាផ្ទាល់ខ្លួនលើការបន្តអភិវឌ្ឍខ្លួនឥតឈប់ឈរ និងរក្សានូវការយល់ដឹងនូវចំណេះវិជ្ជាថ្មីៗដោយធ្វើអោយប្រសើរឡើងនូវចំណេះដឹង ជំនាញ និងអកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ ។

- CPD ជួយអោយអ្នកធ្វើបច្ចុប្បន្នភាពនូវអ្វីដែលអ្នកបានរៀននៅឯសាលា ឬមហាវិទ្យាល័យ ផ្នែកគិលានុបដ្ឋាក ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរលើការអនុវត្ត ការផ្លាស់ប្តូរដែលជាតម្រូវការរបស់អ្នកជម្ងឺ និងសេវាកម្ម និងការផ្លាស់ប្តូរលើការរំពឹងទុករបស់សង្គមលើរបៀបរបបធ្វើការរបស់គិលានុបដ្ឋាកទាំងអស់។
- CPD នឹងជួយអ្នកអោយប្រមើល មើលនិងឆ្លើយតបទៅនឹងតម្រូវការនៃការផ្លាស់ប្តូរទាំងនេះ។ CPD អនុញ្ញាតអោយអ្នករក្សានូវការអនុវត្តដែលទាន់បច្ចុប្បន្នភាព និងសមស្រប និងជួយរក្សានូវស្តង់ដារជីវៈដែលជាតម្រូវការរបស់អ្នកពេញមួយជីវិតនៃអាជីពរបស់អ្នក។

CCN សង្ឃឹមថាគោលការណ៍ណែនាំនេះនឹងជាប្រយោជន៍សម្រាប់ការបង្កើនការអភិវឌ្ឍវិជ្ជាជីវៈនិងការពេញចិត្តលើការងារក្នុងចំណោមគិលានុបដ្ឋាកក្នុងស្រុក និងក្នុងតំបន់។

គោលការណ៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គោលបំណងចម្បងនៃ CPD គឺដើម្បីជួយលើកកម្ពស់សុវត្ថិភាព និងគុណភាពនៃការថែទាំដែលផ្តល់អោយអ្នកជម្ងឺ និងសាធារណជន។

ក .<u>ការទទួលខុសត្រូវលើការរៀនសូត្រផ្ទាល់ខ្លួន</u>

បុគ្គលគ្រប់រូបគឺជាអ្នកទទួលខុសត្រូវលើការកំណត់ពីតម្រូវការ CPD ការរៀបចំធ្វើផែនការដើម្បីធ្វើអោយបានសម្រេចនូវតម្រូវទាំងនោះ និងការអនុវត្តតាម CPD ដែលនឹងគាំទ្រដល់ការអភិវឌ្ឍ និងការការអនុវត្តជំនាញវិជ្ជាជីវៈរបស់ខ្លួន។

ខ. <u>ការឆ្លុះបញ្ចាំង</u>

ការអនុវត្តការថែទាំល្អតម្រូវអោយបុគ្គលឆ្លុះបញ្ចាំងជាប្រចាំលើនិយាមនៃការថែទាំអ្នកជម្ងឺ។

គ. <u>វិសាលភាពនៃការថែទាំ</u>

បុគ្គលគ្រប់រូបត្រូវតែមានសមត្ថភាព និងការអនុវត្តប្រកបដោយបច្ចុប្បន្នភាពគ្រប់ផ្នែកទាំងអស់។

ឃ. <u>ការរៀនសូត្រលក្ខណៈបុគ្គល និងក្រុម</u>

សកម្មភាព CPD របស់បុគ្គលម្នាក់គួរតែមានគោលបំណងដើម្បីថែរក្សា និងកែលម្អនិយាមនៃការថែទាំអ្នកជម្ងឺផ្ទាល់ខ្លួន ហើយក៏សម្រាប់ក្រុមផ្សេងៗទៀតនៅកន្លែងធ្វើការរបស់អ្នកដែរ។

ង. <u>ការកំណត់កម្រិតការ</u>

សកម្មភាព CPD របស់បុគ្គលម្នាក់គួរតែអនុវត្តអោយស្របតាមការវាយតម្លៃទាំងតម្រូវការវិជ្ជាជីវៈ និងតម្រូវការនៃសេវាកម្ម និងប្រជាពលរដ្ឋដែលប្រើប្រាស់វា។

ច. <u>លទ្ធផល</u>

បុគ្គលម្នាក់ៗត្រូវឆ្លុះបញ្ចាំងពីអ្វីដែលខ្លួនបានរៀនតាមរយៈ CPD របស់ខ្លួននិងកត់ត្រានូវរាល់ផលប៉ះពាល់ណាមួយ (ឬការរំពឹងទុកលើផលប៉ះពាល់នាពេលអនាគត) លើការប្រព្រឹត្ត និងការអនុវត្តរបស់បុគ្គលម្នាក់ៗ។

គោលដៅការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គោលដៅរបស់ CPD គឺជាប់ទាក់ទងនឹងការធ្វើអោយប្រសើរឡើងនូវការអនុវត្តការងារ ការបង្កើនការរំពឹងទុកលើវិជ្ជាជីវៈ ការបង្កើនសមត្ថភាពលើការរៀនសូត្រ ការលើកទឹកចិត្តអោយមានការចូលរួម និងការប្តេជ្ញាចិត្តលើការបន្តការរៀនសូត្រពេញមួយជីវិត និងការសម្របខ្លួន និងរៀបចំខ្លួនសម្រាប់ការផ្លាស់ប្តូរក្នុងការថែទាំសុខភាព។

សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត

CCN ទទួលស្គាល់នូវសកម្មភាព CPD ផ្សេងៗគ្នា ដែលមានចែងជាទូទៅក្នុងកម្រិតបីខាងក្រោម៖

កម្រិតទី១៖ សកម្មភាពលើសេវាថែទាំ ឬការថែទាំសុខភាពដើម្បីទទួលបានចំណេះដឹង និងសមត្ថភាពជំនាញវិជ្ជាជីវៈ។

កម្រិតទី២៖ សកម្មភាពក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈថែទាំ និងការអភិវឌ្ឍបុគ្គលិក

កម្រិតទី៣៖ ការសិក្សាស្ថាប័នសកម្មភាពខាងក្រោម ជាឧទាហរណ៍នៃសកម្មភាពដែល**<u>មិនមាន</u>**លក្ខណៈគ្រប់គ្រាន់សម្រាប់ CPD៖

- ការងារជាប្រចាំរាល់ថ្ងៃ
- កិច្ចការដែលបានសរសេរ (written assignment)
- ការចងក្រងសៀវភៅណែនាំលើការបណ្តុះបណ្តាលសិស្សសម្រាប់ប្រើប្រាស់ផ្ទៃក្នុង
- ដំណើរទស្សនកិច្ច និង/ឬការទស្សនាការតាំងពិពណ៌ និងការធ្វើបទបង្ហាញលើបច្ចេកវិទ្យា
- ភាពជាសមាជិកនៃអង្គភាពវិជ្ជាជីវៈ ក្រុមប្រឹក្សា ឬសមាគមជំនាញវិជ្ជាជីវៈ
- កិច្ចប្រជុំរៀបចំឡើងដោយក្រុមហ៊ុនឱសថ និងក្រុមហ៊ុនផលិត ឬអ្នកនាំចូលផលិតផល និងឧបករណ៍បច្ចេកទេស (រួមបញ្ចូលទាំងឧបករណ៍បច្ចេកវិទ្យាជំនួយ) ឬតំណាងចែកចាយផ្តាច់

មុខក្នុងគោលបំណងនៃការធ្វើទីផ្សារ និង/ឬការផ្សព្វផ្សាយផលិតផលរបស់ពួកគេ មិនមានលក្ខណៈស្របច្បាប់សម្រាប់ទទួលគុណភាព។

លក្ខណៈវិនិច្ឆ័យ/តម្រូវការ និងការទទួលស្គាល់

CPD ជាតម្រូវការដើម្បីរក្សា និងពង្រឹងស្តង់ដារវិជ្ជាជីវៈរបស់គិលានុបដ្ឋាក និងដើម្បីផ្តល់នូវសុវត្ថិភាព និងគុណភាពនៃសេវាថែទាំ។ CPD ក៏ចូលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់គិលានុបដ្ឋាកម្នាក់ៗផងដែរ។ ច្បាប់ថ្មីស្តីពីការគ្រប់គ្រងអ្នកអនុវត្តវិជ្ជាជីវៈសុខាភិបាលនឹងតម្រូវអោយគិលានុបដ្ឋាកគ្រប់រូបបំពេញគ្រប់សកម្មភាព CPD ដើម្បីមានសិទ្ធិស្របច្បាប់ក្នុងការទទួលបានអាជ្ញាបណ្ណដើម្បីអនុវត្តការថែទាំ។ ការខកខានក្នុងការបំពេញតាមតម្រូវការស្របតាមគោលការណ៍ណែនាំស្តីពី CPD របស់ CCN សម្រាប់គិលានុបដ្ឋាកនឹងពុំត្រូវបានផ្តល់អាជ្ញាបណ្ណជាគិលានុបដ្ឋាកសាជាថ្មីនោះឡើយ ហើយគិលានុបដ្ឋាកនឹងពុំមានសិទ្ធិអនុវត្តជំនាញវិជ្ជាជីវៈតទៅទៀតនោះទេ។

ជំហានដែលគិលានុបដ្ឋាកត្រូវអនុវត្តតាម៖

ប្រសិនបើអ្នកពុំទាន់បានចុះបញ្ជិកាជាគិលានុបដ្ឋាកជាមួយ CCN សូមទៅធ្វើការចុះបញ្ជិកាជាគិលានុបដ្ឋាកអោយស្របតាមនីតិវិធីនៃការចុះបញ្ជិការបស់ CCN (ឧបសម្ព័ន្ធទី១) បន្ទាប់មកសូមអនុវត្តតាមជំហានខាងក្រោម។

ប្រសិនបើអ្នកបានចុះបញ្ជិកាជាមួយ CCN រួចហើយនោះ សូមទាញយកនូវឯកសារមួយចំនួនខាងក្រោមពីគេហទំព័ររបស់ CCN http://cambodiancouncilofnurse.com/ និងបោះពុម្ព (Print) វា ។

១. គោលការណ៍ណែនាំស្តីពី CPD សម្រាប់គិលានុបដ្ឋាក

២. កំណត់ត្រាសកម្មភាពរបស់បុគ្គល (ឧបសម្ព័ន្ធទី២)

មានការរំពឹងទុកថាគិលានុបដ្ឋាកម្នាក់ៗនឹងប្រមូលចំនួនពិន្ទុ អោយបាន **៦០ពិន្ទុ ក្នុងរយៈពេល៣ឆ្នាំ ឬ២០ពិន្ទុ** ក្នុង១ឆ្នាំ។ ចំនួន ពិន្ទុ ទាំងនេះអាចប្រមូលបានតាមការចូលរួមក្នុងសកម្មភាពផ្សេងៗ សូមមើលតារាងទិដ្ឋភាពទូទៅនៃចំនួនពិន្ទុប្រព័ន្ធ credit។

សូមបំពេញនូវសកម្មភាពក្នុងកំណត់ត្រាសកម្មភាពបុគ្គលម្នាក់ៗ (ឧបសម្ព័ន្ធទី២) និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្សេងៗដូចជា វិញ្ញាបនបត្រនៃការចូលរួម និងលិខិតសរសើរ ឬឯកសារចម្លងពីអត្ថបទកាសែតដែលបានចេញផ្សាយ សេចក្តីថ្លែងការណ៍នៃការងារជាសាស្ត្រាចារ្យ ឬអ្នកបង្វឹកការងារ ឬពានរង្វាន់ជាផ្លូវការមួយដែលបញ្ជាក់ថាបានបញ្ចប់ការសិក្សា ឬការងាររហូតដល់ថ្ងៃនេះសម្រាប់សកម្មភាព CPD។

ចំណាំ៖ សកម្មភាព CPD ត្រូវតែបានទទួលស្គាល់ដោយ CCN តាមរយៈអ្នករៀបចំកម្មវិធី (មិនមែនតាមរយៈគិលានុបដ្ឋាកនោះទេ)។ គ្រប់អ្នករៀបចំកម្មវិធី ត្រូវទាក់ទងមក CCN ដើម្បីអោយមានការយល់ស្របទទួលស្គាល់លើសកម្មភាពមុនពេលអនុវត្តសកម្មភាពនោះ ដូច្នេះពិន្ទុ CPD នឹងត្រូវបានទទួលស្គាល់រួចជាស្រេច។
សូមទំនាក់ទំនងមកកាន់ CCN តាមរយៈ info@cambodiancouncilofnurse.com

សូមកត់ចំណាំថា CCN នឹងទទួលស្គាល់អ្នកផ្តល់សកម្មភាព CPD ដ៏ជាក់លាក់មួយចំនួនរួមមាន ក្រសួងសុខាភិបាល (MoH) សាកលវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់ (RTCs) សមាគមជំនាញវិជ្ជាជីវៈអន្តរជាតិ តំបន់ និងកម្ពុជាសម្រាប់គិលានុបដ្ឋាក និងម្ចាស់ជំនួយផ្នែកសុខាភិបាល។

នៅពេលផ្តល់អាជ្ញាបណ្ណឡើងវិញនៅតាមការិយាល័យចុះឈ្មោះតាមបណ្តាខេត្ត-ក្រុង សូមភ្ជាប់មកជាមួយនូវកំណត់ត្រាសកម្មភាពបុគ្គល និងវិញ្ញាបនបត្រនៃការចូលរួម។

នៅពេលដែលគ្រប់ឯកសារដែលទាក់ទងនឹង CPD ត្រូវបានផ្ទៀងផ្ទាត់ដោយការិយាល័យចុះឈ្មោះខេត្ត-ក្រុង និងឯកសារនៃការចុះឈ្មោះគ្រប់គ្រាន់ហើយ អ្នកមានសិទ្ធគ្រប់គ្រាន់ស្របច្បាប់ក្នុងការទទួលបានការផ្តល់អាជ្ញាបណ្ណគិលានុបដ្ឋាកជាថ្មី។

ទំនាក់ទំនងសំខាន់ៗ៖

Cambodian Council of Nurses:

បន្ទប់ ៥០៧ ជាន់ទី៥ Pearla Palace Condo

#672, ផ្លូវ៣៦៦ សង្កាត់ទួលស្វាយព្រៃ១ ខ័ណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទ៖ ០១១៤២៤២២២/ ០១២៧៦៨៣៨៧/ ០១២៩២៥៨៦៣

អ៊ីម៉ែល៖ info@cambodiancouncilofnurse.com

គេហទំព័រ៖ http://cambodiancouncilofnurse.com/

ហ្វេសប៊ុក៖ **គណៈគិលានុបដ្ឋាកកម្ពុជា -គគិក**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



គណៈគិលានុបដ្ឋាកកម្ពុជា

សេចក្តីសម្រេច

ស្តីពី

និយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

សម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ

ខែ វិច្ឆិកា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ
លេខ ក.គ.គជ./១៩

សេចក្តីសម្រេច
ស្តីពី
និយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត
សម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ

ប្រធានគណៈគិលានុបដ្ឋាកកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រម លេខ នស/រកម/១១០០/១០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រម នស/រកម/១១១៦/០១៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ប្រកាសអោយប្រើច្បាប់ស្តីពីច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៧៣ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការ បង្កើតគណៈគិលានុបដ្ឋាកកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញសេចក្តីសម្រេច លេខ ០៧៦ អបស.អធម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ ស្តីពីការតែងតាំង គណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាល
- យោងតាមការចាំបាច់របស់គណៈគិលានុបដ្ឋាកកម្ពុជា

សម្រេច
ផ្នែកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ ១

សេចក្តីសម្រេចនេះមានគោលបំណងគ្រប់គ្រង និងជម្រុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល និងកំណត់និយាមអប្បបរមាដើម្បីស្នើសុំ និងបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ។

ប្រការ ២

និយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តមានវិសាលភាពអនុវត្តចំពោះអ្នកប្រកបវិជ្ជាជីវៈថែទាំទាំងវិស័យសុខាភិបាលសាធារណៈ ឯកជន អង្គការនានា និងដៃគូអភិវឌ្ឍវិស័យសុខាភិបាល ទោះជាទទួល ឬមិនទទួលបានកម្រៃពីការងារនោះក៏ដោយ។

និយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះ មិនអនុវត្តចំពោះអ្នកវិជ្ជាជីវៈថែទាំដែលមិនប្រកបវិជ្ជាជីវៈថែទាំនោះទេ។

ប្រការ ៣

ដើម្បីបំពេញតាមនិយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកបវិជ្ជាជីវៈថែទាំសញ្ជាតិខ្មែរដែលមានអាជ្ញាបណ្ណ ត្រូវបំពេញសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ឱ្យបានយ៉ាងតិច ៦០(ហុកសិប)ពិន្ទុរៀងរាល់ រដ្ឋឆ្នាំ។

ចំពោះអ្នកប្រកបវិជ្ជាជីវៈថែទាំជាជនបរទេស តម្រូវបំពេញសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត យ៉ាងតិច ២០(ម្ភៃ)ពិន្ទុ រៀងរាល់រដ្ឋ១ឆ្នាំ។

ប្រការ ៤

ក្នុងករណីអ្នកមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល លើសពីមួយ សាមីខ្លួនត្រូវបំពេញសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តដែលតម្រូវដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ ។

ចំពោះសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈលើសពីមួយ អ្នកប្រកបវិជ្ជាជីវៈថែទាំអាចរាប់សកម្មភាពនោះជាកត្តាងនៃពិន្ទុអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ។

ប្រការ ៥

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងសេចក្តីសម្រេចនេះមាននិយមន័យដូចតទៅ៖

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត សំដៅដល់ដំណើរការនៃការសិក្សាពេញមួយជីវិត ដែលមានគោលបំណងរក្សា និងលើកកម្ពស់នូវការអនុវត្តរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលតាមរយៈការពង្រីកចំណេះដឹង (ការស្រាវជ្រាវ ជំនាញវិជ្ជាជីវៈ សមត្ថភាពវិជ្ជាជីវៈ) ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ។

ការប្រកបវិជ្ជាជីវៈ ក្នុងបរិបទនេះសំដៅដល់ រាល់តួនាទីដែលបុគ្គលម្នាក់ៗប្រើជំនាញ និងចំណេះដឹងជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ក្នុងវិជ្ជាជីវៈរបស់ពួកគេ។

ការប្រកបវិជ្ជាជីវៈ មិនសំដៅតែការផ្តល់សេវាព្យាបាល ថែទាំវេជ្ជសាស្ត្រ ជាមួយអតិថិជនដោយផ្ទាល់នោះទេ ដោយរាប់បញ្ចូលទាំងការងារគ្រប់គ្រងរដ្ឋបាល អប់រំ/បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់ប្រឹក្សា អភិវឌ្ឍគោលនយោបាយ ឬ បទប្បញ្ញត្តិ និងតួនាទីផ្សេងៗទៀត ដែលប៉ះពាល់ដល់សុវត្ថិភាព ប្រសិទ្ធភាពនៃការផ្តល់សេវាតាម រយៈវិជ្ជាជីវៈនោះ ទោះជាបានឬមិនបានទទួលកម្រៃក៏ដោយ។

អ្នកវិជ្ជាជីវៈថែទាំ សំដៅដល់គិលានុបដ្ឋាកទន្តគិលានុបដ្ឋាក ដែលទទួលបានការចុះបញ្ជីកាជាមួយគណៈគិលានុបដ្ឋាកកម្ពុជា។

អ្នកប្រកបវិជ្ជាជីវៈថែទាំ សំដៅដល់អ្នកវិជ្ជាជីវៈថែទាំដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ។

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈគិលានុបដ្ឋាកកម្ពុជា ទទួលស្គាល់ គឺជាអង្គភាព ឬដៃគូជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាវិជ្ជាជីវៈថ្នាក់ជាតិថាបានបំពេញតាមបទដ្ឋានដែលតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាពដល់អ្នកប្រកបវិជ្ជាជីវៈថែទាំ ។ អង្គភាព និងដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈគិលានុបដ្ឋាកកម្ពុជា ទទួលស្គាល់អាចផ្តល់នូវសកម្មភាពវិជ្ជាជីវៈជាក់លាក់ ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តឬទាំងពីរ។

ផ្នែកទី២
បេសកកម្ម

ប្រការ ៦

អ្នកបញ្ចប់ការសិក្សាមិនលើសពី (បី) ៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការសិក្សាដោយជោគជ័យនៃគុណវុឌ្ឍិ មិនត្រូវឱ្យបំពេញតាមនិយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះទេ នៅពេលដែលសាមីខ្លួនស្នើសុំចុះបញ្ជិកា និងសុំអាជ្ញាបណ្ណដើម្បីប្រកបវិជ្ជាជីវៈលើកដំបូង។

ប្រការ ៧

អ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់ត្រូវស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈយ៉ាងតិច ៣ (បី) ខែមុនពេលអាជ្ញាបណ្ណអស់សុពលភាព។ នៅពេលស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈអ្នកប្រកបវិជ្ជាជីវៈថែទាំ ត្រូវប្រកាសនិងផ្តល់ឯកសារភ័ស្តុតាងដែលបង្ហាញថាសាមីខ្លួនបានអនុវត្តតាមនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

ក្នុងករណីដែលអ្នកប្រកបវិជ្ជាជីវៈថែទាំមិនបានបំពេញពិន្ទុគ្រប់ចំនួនតាមលក្ខខណ្ឌគណៈគិលានុបដ្ឋាកកម្ពុជានឹងមិនបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈជូនឡើយ។

ប្រការ ៨

អ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់តម្រូវអោយរក្សាទុកនូវឯកសារកំណត់ត្រានៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្លួនយ៉ាងហោចណាស់បានរយៈពេល ៣(បី)ឆ្នាំ។

ប្រការ ៩

គណៈគិលានុបដ្ឋាកកម្ពុជា ត្រូវរក្សាទុកកំណត់ត្រារបស់អ្នកប្រកបវិជ្ជាជីវៈថែទាំដែលបានត្រួតពិនិត្យរួចសម្រាប់ការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំឬការធ្វើសវនកម្ម និងបញ្ជីអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ និងកម្មវិធីឬវគ្គបណ្តុះបណ្តាលដែលបានអនុម័តដោយគណៈគិលានុបដ្ឋាកកម្ពុជា។

ប្រការ ១០

ការអនុលោមតាមនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត គណៈគិលានុបដ្ឋាកកម្ពុជាអាចធ្វើសវនកម្មបានគ្រប់ពេល ឬ នៅពេលទទួលបានបណ្តឹងដែលពាក់ព័ន្ធនឹងសម្បទា ឬកំហុសឆ្គងក្នុងការប្រកបវិជ្ជាជីវៈថែទាំ។

ប្រការ ១១

គណៈគិលានុបដ្ឋាកកម្ពុជានឹងកំណត់លក្ខខណ្ឌ និងដំណើរការដាក់លាក់ នៃការស្នើសុំ ដើម្បីទទួលស្គាល់ជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងជាតិនិងអន្តរជាតិ ព្រមទាំងការផ្តល់ពិន្ទុសម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ប្រការ ១២

ករណីអ្នកប្រកបវិជ្ជាជីវៈថែទាំ មិនបានបំពេញតាមនិយាមអប្បបរមានៃការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ចាត់ទុកថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈថែទាំ។

ប្រការ ១៣

គណៈគិលានុបដ្ឋាកកម្ពុជាអាចដាក់ទណ្ឌកម្មខាងវិន័យមួយឬច្រើន យោងតាមមាត្រា១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ក្នុងករណីអ្នកប្រកបវិជ្ជាជីវៈថែទាំណាម្នាក់មិនបានបំពេញតាមនិយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

ប្រការ ១៤

គណៈគិលានុបដ្ឋាកកម្ពុជាជាអ្នករៀបចំ៖

- គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ
- គោលការណ៍ណែនាំសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- សាលាកបត្រព័ត៌មាន

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាផ្នែកមួយនៃការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈរៀងរាល់ ៣(បី)ឆ្នាំម្តង សម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ។

ផ្នែកទី៣
អវសានប្បញ្ញត្តិ

ប្រការ ១៥

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

សេចក្តីសម្រេចនេះនឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស២៥៦.៣
រាជធានីភ្នំពេញថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩

ជ.ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ

ប្រធាន



អនុបណ្ឌិត អ៊ុន សាន

ចម្លងជូន

- គណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាល
- គណៈគិលានុបដ្ឋាកកម្ពុជា រាជធានី ខេត្ត
- មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ
- មន្ទីរសុខាភិបាលនៅរាជធានី ខេត្ត
- គ្រប់មហាវិទ្យាល័យទាំងសាធារណៈ និង ឯកជន
- សមាគមវិជ្ជាជីវៈសុខាភិបាល
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



គណៈគិលានុបដ្ឋាកកម្ពុជា

គោលការណ៍ណែនាំ
ស្តីពី
ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ខែ វិច្ឆិកា ឆ្នាំ២០១៩

សេចក្តីផ្តើម

អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល គណៈគិលានុបដ្ឋាកកម្ពុជា មានតួនាទី ជានិយតករក្នុងការបង្កើតលក្ខខណ្ឌតម្រូវនានា សម្រាប់អ្នកវិជ្ជាជីវៈថែទាំ និងអ្នកប្រកបវិជ្ជាជីវៈថែទាំ ក្នុងការផ្តល់សេវាប្រកបដោយសុវត្ថិភាព ។

តួនាទីទាំងនេះរួមមាន៖

- ចុះបញ្ជិកាអ្នកវិជ្ជាជីវៈថែទាំទាំងអស់
- ចេញអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ចំពោះអ្នកវិជ្ជាជីវៈថែទាំទាំងឡាយណា ដែលបានចុះបញ្ជិការួចហើយ
- ធានាថាអ្នកប្រកបវិជ្ជាជីវៈថែទាំដែលបានចុះបញ្ជិកា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈទាំងអស់ បំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមា ដើម្បីបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំរបស់ខ្លួនយ៉ាងទៀងទាត់
- គ្រប់គ្រងការប្រកបវិជ្ជាជីវៈរបស់អ្នកវិជ្ជាជីវៈថែទាំ និងអ្នកប្រកបវិជ្ជាជីវៈថែទាំតាមរយៈ ការបង្កើត ក្រមសេចក្តីសម្រេច និយាម គោលការណ៍ណែនាំ និងបទដ្ឋាននានារបស់គណៈគណៈគិលានុបដ្ឋាកកម្ពុជា សម្រាប់ការប្រកបវិជ្ជាជីវៈថែទាំ
- ស៊ើបអង្កេតបណ្តឹង ដែលពាក់ព័ន្ធនឹងសម្បទា សមត្ថភាព និងការប្រព្រឹត្ត របស់អ្នកប្រកបវិជ្ជាជីវៈថែទាំ ដើម្បីអាចដាក់ទណ្ឌកម្មខាងវិន័យ ឬ/និងគាំពារ ឱ្យបានសមស្រប ។

គោលការណ៍ណែនាំទាំងនេះ បំពេញបន្ថែមនូវនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់គណៈគិលានុបដ្ឋាកកម្ពុជា និងផ្តល់ព័ត៌មានបន្ថែមទៀតអំពីលក្ខខណ្ឌតម្រូវអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់គណៈគិលានុបដ្ឋាកកម្ពុជា សម្រាប់រយៈពេល ៣ ឆ្នាំ។

គោលការណ៍ណែនាំនេះពន្យល់ប្រាប់ថា តើអ្នកប្រកបវិជ្ជាជីវៈថែទាំអាចបំពេញតាមលក្ខខណ្ឌតម្រូវរបៀបណាដើម្បីធានាថា ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ពាក់ព័ន្ធនឹងវិជ្ជាជីវៈព្រមទាំងបង្កើនចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈរបស់ពួកគេ ក្នុងការផ្តល់សេវាសុខាភិបាល ទៅដល់អ្នកជំងឺ ឬ អតិថិជន ស្របតាមក្រមសីលធម៌ បទដ្ឋាន ច្បាប់ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ។

១. ការអនុវត្តគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គោលការណ៍ណែនាំទាំងនេះប្រើសម្រាប់គិលានុបដ្ឋាកទាំងអស់ដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ។ អ្នកប្រកបវិជ្ជាជីវៈថែទាំម្នាក់ៗនឹងស្វែងយល់ ហើយអាចអនុវត្តតាមគោលការណ៍ណែនាំទាំងនេះ ដោយអនុលោមតាមនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់គណៈគិលានុបដ្ឋាកកម្ពុជា។

២. ភាតព្វកិច្ចរបស់អ្នកប្រកបវិជ្ជាជីវៈថៃទាំ

អ្នកប្រកបវិជ្ជាជីវៈថៃទាំ ត្រូវបំពេញសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដើម្បីឱ្យស្របតាមនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់គណៈគិលានុបដ្ឋាកកម្ពុជា សម្រាប់រយៈពេល ៣ ឆ្នាំនៃវដ្តនីមួយៗ។ សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងនេះត្រូវតែពាក់ព័ន្ធនឹងវិជ្ជាជីវៈថៃទាំ តម្រូវការការសិក្សារបស់បុគ្គលម្នាក់ៗ និងត្រូវតែបំពេញឱ្យបានគ្រប់មុនពេលបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថៃទាំ។

៣. ឥដ្ឋ ពិន្ទុ និងចំនួនម៉ោងរៀនសកម្ម នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

វដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនីមួយៗ ចាប់ផ្តើមពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនីមួយៗ ត្រូវបានផ្តល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា រហូតដល់កាលបរិច្ឆេទដែលអាជ្ញាបណ្ណអស់សុពលភាព ។

អ្នកប្រកបវិជ្ជាជីវៈថៃទាំដែលជាជនបរទេស តម្រូវឱ្យបំពេញពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត អប្បបរមា ២០ពិន្ទុ ក្នុងវដ្ត ១ ឆ្នាំ ។

អ្នកប្រកបវិជ្ជាជីវៈថៃទាំដែលមានសញ្ជាតិខ្មែរ តម្រូវឱ្យបំពេញពិន្ទុ ការអភិវឌ្ឍវិជ្ជាជីវៈបន្ត សរុប ៦០ ពិន្ទុ អំឡុងពេល ៣ ឆ្នាំ ។

សម្រាប់ឆ្នាំនីមួយៗនៃវដ្តការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកបវិជ្ជាជីវៈថៃទាំដែលមានសញ្ជាតិខ្មែរ តម្រូវឱ្យបំពេញពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត អប្បបរមា ១៥ ពិន្ទុរៀងរាល់ឆ្នាំ ។

១ ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត គឺស្មើនឹង១ម៉ោងនៃការរៀនសកម្ម មានន័យថា៦០ ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងរយៈពេល ៣ឆ្នាំ ស្មើនឹង ៦០នៃម៉ោងរៀនសកម្ម ។ពិន្ទុសរុបលើសក្នុងវដ្តមួយមិនអាចផ្ទេរ ទៅវដ្តបន្ទាប់បានទេ ។

៤. ប្រភេទសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការឱ្យពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គណៈគិលានុបដ្ឋាកកម្ពុជា តម្រូវឱ្យអ្នកប្រកបវិជ្ជាជីវៈថៃទាំម្នាក់ៗចូលរួមសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តផ្សេងៗដែល៖ (១) ពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈបច្ចុប្បន្ន និងអនាគត និង(២)ឆ្លើយតបទៅនឹងតម្រូវការសិក្សាដែលបានកំណត់។ សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងនេះត្រូវបានគេរំពឹងថានឹងពង្រីកចំណេះដឹងវិជ្ជាជីវៈថៃទាំ ដែលមានស្រាប់ និងមិនមែនជាផ្នែកនៃតម្រូវការការងារប្រចាំថ្ងៃឡើយ ។

សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាច្រើនដែលត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា ដូចមាននៅក្នុងតារាងខាងក្រោមដើម្បីជាមគ្គុទ្ទេសក៍។ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តនីមួយៗ គឺអាស្រ័យលើចំនួនម៉ោងជាក់ស្តែងដែលអ្នកប្រកបវិជ្ជាជីវៈថៃទាំចូលរួមយ៉ាងសកម្មនៅក្នុង

សកម្មភាពសិក្សា។ ពេលវេលាចំណាយសម្រាប់សកម្មភាពកម្មវិធីដូចជា ការចុះឈ្មោះ ការសម្រាកពិសាអាហារ សម្រន់ សុន្ទរកថានិងកម្មវិធីផ្សេងៗ មិនត្រូវបានទទួលស្គាល់ថាជាការរៀនសកម្ម និងមិនអាចចាត់ចូលជាពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តបានទេ ។ ឧទាហរណ៍៖ សិក្ខាសាលាដែលមានរយៈពេល ១ ថ្ងៃ ឬ ៨ ម៉ោង ដែលក្នុងនោះរាប់បញ្ចូលទាំង ២ ម៉ោងនៃការពិសាអាហារ សម្រាកអាហារសម្រន់ និង ១ម៉ោងសម្រាប់សុន្ទរកថា នោះបានន័យថាសកម្មភាពរៀនសកម្មមានតែ៥ម៉ោងប៉ុណ្ណោះ ហើយក៏បានន័យថា ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសរុបសម្រាប់សិក្ខាសាលានេះ គឺ ៥ ពិន្ទុ ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តខ្លះ ដែលមាននៅក្នុងតារាងខាងក្រោម រួមបញ្ចូលចំនួនអតិបរមានៃពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលត្រូវបានឱ្យ ដែលមិនគិតពីចំនួនម៉ោងសរុបនៃការរៀនសូត្រសកម្ម ។
ឧទាហរណ៍៖ វគ្គបណ្តុះបណ្តាលរយៈពេល ៤ ថ្ងៃ ដែលមានការរៀនសូត្រសកម្មសរុប អាចដល់២៤ ម៉ោងស្មើនឹង ២៤ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ទោះយ៉ាងនេះក្តី ពិន្ទុអតិបរមានៃពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដែលមានរយៈពេលពី ១ ថ្ងៃ ទៅ ≤ ២សប្តាហ៍ គឺ ១៥ ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។ ដូច្នេះវគ្គបណ្តុះបណ្តាលរយៈពេល ៤ ថ្ងៃ នឹងត្រូវបានគេឱ្យពិន្ទុចំនួនអតិបរមា១៥ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

នៅពេលបញ្ចប់ការសិក្សាដោយជោគជ័យ មានការវាយតម្លៃចំណេះដឹង (Post Test) ដែលជាផ្នែកនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាប់ជាផ្លូវការ ដោយមានកស្តុតាងបង្ហាញ នោះសិក្ខាកាមអាចទទួលបាន ២(ពីរ) ពិន្ទុបន្ថែមទៀត លើពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសរុប ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការបែងចែកពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ល.រ	សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត	ចំនួនពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត [១ ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត=១ ម៉ោង នៃការរៀនសកម្ម]	ចំនួនពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អតិបរមា
១	ការពិភាក្សាករណីសិក្សាជាក្រុម/ ចូលរួមការប្រជុំបច្ចេកទេស (កូឡូក)	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
២	ការសិក្សាដោយខ្លួនឯង* (អានអត្ថបទទិនានុប្បវត្តិ នៅក្នុងទិនានុប្បវត្តិល្បីៗទាក់ទងនឹងសុខភាពឬការបោះពុម្ពផ្សាយ តាមអ៊ីនធឺណិតទាក់ទងនឹងសុខភាព ឬ វេប៊ីណា (**Webinars**) ឬ វីដេអូទាក់ទងនឹងសុខភាព) * ត្រូវការកស្តុតាងជាលាយលក្ខណ៍អក្សរ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១០ ពិន្ទុ
៣	សិក្ខាសាលាបណ្តុះបណ្តាល ដែលមានរយៈពេល ១ថ្ងៃ - ២សប្តាហ៍	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១៥ពិន្ទុ

៤	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល > ២សប្តាហ៍ ទៅ ៣ខែ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ២៥ពិន្ទុ
៥	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល > ៣ខែ ទៅ ៦ខែ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ៣៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ៣៥ពិន្ទុ
៦	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល >៦ ទៅ ១២ខែ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ៤៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ៤៥ពិន្ទុ
៧	ចូលរួមការអប់រំនៅកន្លែងធ្វើការ វគ្គសិក្សាក្នុងពេលបំពេញការងារ(In-service training) ឬកម្មវិធីអភិវឌ្ឍជំនាញ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់ម៉ោងរៀនសកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
៨	ចូលរួមសន្និសីទក្នុងប្រទេសកម្ពុជា	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
៩	ចូលរួមសន្និសីទ សន្និបាត មហាសន្និបាត ក្រៅប្រទេស	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ២០ពិន្ទុ
១០	ស្រាវជ្រាវ រៀបចំ សម្រាប់ធ្វើបទបង្ហាញនៅម៉ោងបង្រៀន ឬបទបង្ហាញក្នុងសន្និសីទជាតិ ឬអន្តរជាតិ (ដែលមិនមែនជាផ្នែកនៃការបង្រៀនដូចធម្មតា)	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងស្រាវជ្រាវរៀបចំដើម្បីធ្វើបទបង្ហាញ រហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១០ពិន្ទុ
១១	ចូលរួមជាសមាជិកក្នុងក្រុមស្រាវជ្រាវ ឬការងារគម្រោងទាក់ទងនឹងសុខភាព	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១០ពិន្ទុ
១២	ចូលរួមជាសមាជិកក្នុងក្រុមក្នុងការ បង្កើតគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំនានាទាក់ទងនឹងសុខភាព	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១០ពិន្ទុ
១៣	ស្រាវជ្រាវបន្ថែមនិងរៀបចំ ដើម្បីអភិវឌ្ឍតួនាទីជាគ្រូណែនាំតាមមន្ទីរពេទ្យ គ្រូណែនាំគ្រូបង្វឹកបុគ្គលិកឬនិស្សិត ហើយមានផែនការបណ្តុះ បណ្តាលដែលមានឯកសារត្រឹមត្រូវ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១០ពិន្ទុ
១៤	ចូលរួមពិនិត្យ និងកែសម្រួលឯកសារអប់រំពាក់-ព័ន្ធនឹងសុខាភិបាល អត្ថបទទិនានុប្បវត្តិ ដំពូកក្នុងសៀវភៅ ឬឯកសារសិក្សាស្រាវជ្រាវ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១៥ពិន្ទុ
១៥	ក្នុងនាមជាសហនិពន្ធ ចុះផ្សាយឯកសារ ឬរបាយការណ៍ ពាក់ព័ន្ធនឹងសុខាភិបាល	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ១៥ពិន្ទុ

១៦	សរសេរអត្ថបទស្រាវជ្រាវ ជំពូកសៀវភៅ ឬរបាយការណ៍ក្នុងនាមជា អ្នកនិពន្ធទី១ ហើយបញ្ជូនដើម្បីចុះផ្សាយ	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ២០ពិន្ទុ
១៧	ចុះផ្សាយឯកសារ ជំពូកសៀវភៅ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខាភិបាលក្នុងនាមជាអ្នកនិពន្ធទី១	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ២០ពិន្ទុ
១៨	ជាប្រធានដឹកនាំក្នុងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងសុខភាព	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ២៥ពិន្ទុ
១៩	ជាប្រធានសម្របសម្រួលក្នុងការធ្វើគម្រោងទាក់ទងនឹងសុខភាព	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ២៥ពិន្ទុ
២០	រៀនវគ្គក្រោយឧត្តមសិក្សាដែលពាក់ព័ន្ធនឹងជំនាញ នៅក្នុងប្រទេស ឬក្រៅប្រទេស ដែលទទួលបានគុណវុឌ្ឍិជាផ្លូវការ ដូចជា បរិញ្ញាបត្រ សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬ បណ្ឌិត	១ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ៦០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងរហូតដល់អតិបរមា ៦០ពិន្ទុ

ការផ្តល់សកម្មភាព និងពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត នឹងត្រូវអនុវត្តជាចម្បងតាមរយៈ៖

- ការសិក្សាជាមួយគ្រូ ឬ អ្នកសម្របសម្រួលដោយផ្ទាល់ ឬការរៀនដោយខ្លួនឯង
- ការរៀន និងការបណ្តុះបណ្តាលពីចម្ងាយ(Online training)និងការសិក្សាជាក្រុម ដោយការធ្វើបទបង្ហាញតាមវីដេអូ

ចំពោះសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតាមរយៈការបណ្តុះបណ្តាលពីចម្ងាយ(Online training) ចាំបាច់ត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីសកម្មភាព (វិញ្ញាបនបត្របញ្ចប់ការសិក្សា និងការវាយតម្លៃ)។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតាមរយៈការបណ្តុះបណ្តាលពីចម្ងាយ(Online training) ដែលជាលក្ខណៈអន្តរជាតិអាចត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា នៅពេលដែលការបណ្តុះបណ្តាលទាំងនោះបានរៀបចំឡើងដោយអ្នកផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានកេរ្តិ៍ឈ្មោះ និងរួមបញ្ចូលការវាយតម្លៃជាឯកសារគណៈគិលានុបដ្ឋាកកម្ពុជា នឹងបង្កើតបញ្ជីសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត នៃការបណ្តុះបណ្តាលពីចម្ងាយ(Online training) ជាបន្តបន្ទាប់ទាំងក្នុងប្រទេសនិងអន្តរជាតិដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់។

ចំនួនពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តការបណ្តុះបណ្តាលពីចម្ងាយ(Online training) គឺអាស្រ័យលើចំនួនម៉ោងដែលបានបញ្ជាក់ដោយអ្នកផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។ ពិន្ទុនេះអាចកើនឡើងទ្វេដង ចំពោះអ្នកប្រកបវិជ្ជាជីវៈថែទាំ ដែលជាជនជាតិខ្មែរ ក្នុងករណីសកម្មភាពសិក្សាតាមអនឡាញជាភាសាអង់គ្លេស ឬបារាំង ។

សម្រាប់អ្នកដែលបានបញ្ចប់ការវាយតម្លៃដោយជោគជ័យនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ហើយបានផ្តល់ឯកសារ

ជាកស្តុតាងទៅគណៈវិជ្ជាជីវៈ នឹងត្រូវបាន ២ពិន្ទុបន្ថែម ។

ឧទាហរណ៍៖ ការបញ្ចប់វគ្គសិក្សាជាភាសាអង់គ្លេសរយៈពេល ២ ម៉ោងតាមអនឡាញ បានពិន្ទុទ្វេដងស្មើនឹង ៤ ពិន្ទុ ហើយការបញ្ចប់ការវាយតម្លៃដោយជោគជ័យបានបន្ថែមចំនួនពិន្ទុ ២ទៀត ដូចនេះពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សរុបគឺ ៦ ពិន្ទុ ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ គឺសកម្មភាពទាំងឡាយណាដែល ពាក់ព័ន្ធនឹងវិជ្ជាជីវៈសុខាភិបាលពីរ ឬច្រើន រួមមាន៖

- ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- ជំងឺឆ្លង
- ជំងឺមិនឆ្លង
- ការស្រាវជ្រាវពាក់ព័ន្ធនឹងសុខាភិបាល
- សុខភាពបន្តពូជ
- សុខភាពមាតា និងទារក
- បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT)
- សុវត្ថិភាព និងសុខភាពការងារ
- ការគ្រប់គ្រងគ្រោះមហន្តរាយ
- ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ
- ការគ្រប់គ្រងគុណភាពសេវាសុខាភិបាល
- ការរៀននិងការបង្រៀន

ការបែងចែកពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់រាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ នឹងត្រូវបានកំណត់ដោយគណៈគិលានុបដ្ឋាកកម្ពុជា ។

៥. សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ចាំបាច់ ដែលគណៈគិលានុបដ្ឋាកកម្ពុជាបានកំណត់

គណៈគិលានុបដ្ឋាកកម្ពុជា អាចកំណត់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលចាំបាច់ប្រសិនបើសកម្មភាពទាំងនោះ ត្រូវបានចាត់ទុកថាជាប្រយោជន៍សាធារណៈ ហើយមានគោលដៅធានាគុណភាព និងសុវត្ថិភាពដល់អ្នកជំងឺ អតិថិជន និង សហគមន៍។

គណៈគិលានុបដ្ឋាកកម្ពុជា នឹងចុះផ្សាយនូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តចាំបាច់ដែលបានកំណត់ខាងលើតាមរយៈ គេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតរបស់គណៈគិលានុបដ្ឋាកកម្ពុជា និងជូនដំណឹងដល់អ្នកប្រកបវិជ្ជាជីវៈថែទាំពាក់ព័ន្ធទាំងអស់ ។

៦. តម្រូវការបន្ថែមឆានាដែលអ្នកប្រកបវិជ្ជាជីវៈថែទាំត្រូវមានលក្ខខណ្ឌលើអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ ក្នុងការបំពេញនូវចំនួនសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ប្រសិនបើអ្នកប្រកបវិជ្ជាជីវៈថែទាំ មានលក្ខខណ្ឌលើអាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈថែទាំ ធ្វើការបំពេញសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត នោះគណៈគិលានុបដ្ឋាកកម្ពុជា នឹងតម្រូវឱ្យពួកគេអនុវត្ត ការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះបន្ថែមលើតម្រូវការ ៦០ ពិន្ទុក្នុងវដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៣ឆ្នាំ ។

៧. ការជ្រើសរើសសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត

រាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវការឯកសារយោងជាក់លាក់ពីអ្នកប្រកបវិជ្ជាជីវៈថែទាំដែលកំណត់ច្បាស់លាស់៖

(១) គោលបំណងនៃសកម្មភាពនេះ
(២) តម្រូវការរៀនសូត្ររបស់បុគ្គល និងផែនការការអភិវឌ្ឍវិជ្ជាជីវៈបន្តផ្ទាល់ខ្លួន
(៣) សកម្មភាពដែលបានចូលរួម
(៤) ពេលវេលាដែលអ្នកបានចូលរួម
(៥) ការសង្ខេបខ្លីពីលទ្ធផលនៃការរៀន

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលពាក់ព័ន្ធនឹងវគ្គបណ្តុះបណ្តាលមានរយៈពេលមួយថ្ងៃ ឬលើស ត្រូវមានឯកសារដែលបង្ហាញពី គោលបំណង និងគោលដៅ ជាមួយអ្នកជំនាញ អ្នកសម្របសម្រួល ឬ/និង អ្នកធ្វើបទបង្ហាញ ដោយរួមបញ្ចូលការវាយតម្លៃដែលបង្ហាញពីការអនុវត្តនូវចំណេះដឹង និងជំនាញថ្មីៗ នៅក្នុងការប្រកបវិជ្ជាជីវៈថែទាំនេះ ។

គណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលជំបូងសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលមានរយៈពេលមួយថ្ងៃ ឬលើស ដែលរួមមាន៖

- ក្រសួងសុខាភិបាល (MoH)
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ: បាត់ដំបង ស្វាយរៀង កំពង់ចាម និងកំពត
- វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ
- សាកលវិទ្យាល័យ ឯកជនដែលផ្តល់ការអប់រំផ្នែកសុខាភិបាល ហើយត្រូវបានអនុញ្ញាតដោយក្រសួងអប់រំយុវជននិងកីឡា (MOEYS) និងក្រសួងសុខាភិបាល
- មន្ទីរពេទ្យរដ្ឋ និងឯកជន
- មន្ទីរសុខាភិបាលខេត្ត
- មន្ទីរពេទ្យបង្អែកខេត្ត
- សមាគមវិជ្ជាជីវៈសុខាភិបាល

ប្រសិនបើអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត មិនមាននៅក្នុងការបរិយាយខាងលើ ពួកគេត្រូវតែធ្វើការជាដៃគូជាមួយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ ឬធ្វើការស្នើសុំទៅគណៈគិលានុបដ្ឋាកកម្ពុជាដើម្បីទទួលស្គាល់ថាជាអ្នកផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

គណៈគិលានុបដ្ឋាកកម្ពុជានឹងមិនទទួលស្គាល់នូវរាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានរៀបចំឡើងដោយក្រុមហ៊ុនឱសថ ឬក្រុមហ៊ុនពាណិជ្ជកម្មតែឯងឡើយ ។

***អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងអស់ ត្រូវតែផ្តល់ឯកសារពាក់ព័ន្ធដែលតម្រូវដោយគណៈវិជ្ជាជីវៈជាមុន ដើម្បីស្នើសុំពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

៨. ការរក្សាទុកឯកសារពាក់ព័ន្ធនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត

អ្នកប្រកបវិជ្ជាជីវៈថែទាំទទួលខុសត្រូវ និងរក្សាទុកឯកសារពាក់ព័ន្ធដើម្បីជា កស្តុតាងនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តឱ្យស្របតាមនិយាមវិជ្ជាជីវៈនីមួយៗ ហើយទទួលខុសត្រូវក្នុងការបង្កើតផែនការសិក្សាផ្ទាល់ខ្លួនដែលកំណត់ពីតម្រូវការសិក្សារបស់សាមីខ្លួន ។

សាមីខ្លួនត្រូវរក្សាកំណត់ត្រានៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរួមជាមួយនឹងឯកសារយោងណាមួយសម្រាប់រយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃដែលអ្នកប្រកបវិជ្ជាជីវៈថែទាំបានបញ្ចប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ការរក្សាកំណត់ត្រានេះ អាចជួយអ្នកប្រកបវិជ្ជាជីវៈថែទាំ ក្នុងការផ្តល់ព័ត៌មាន ប្រសិនបើមានការស្នើសុំពីគណៈគិលានុបដ្ឋាកកម្ពុជា នៅពេលបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ឬអំឡុងពេលសវនកម្មការអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬអំឡុងពេលស៊ើបអង្កេត ឬសវនកម្មលើពាក្យបណ្តឹងប្រឆាំងនឹងអ្នកប្រកបវិជ្ជាជីវៈថែទាំ។

គណៈគិលានុបដ្ឋាកកម្ពុជាបានបង្កើតផែនការសិក្សាផ្ទាល់ខ្លួនមួយ (សូមមើលឧបសម្ព័ន្ធ ក) ដែលជាសកម្មភាព អភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់រយៈពេល ៣ ឆ្នាំនៃវដ្ត (សូមមើលឧបសម្ព័ន្ធ ខ) និងកំណត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតែមួយ (សូមមើលឧបសម្ព័ន្ធ គ) ដែលអាចត្រូវបានប្រើ ដើម្បីជួយរៀបចំផែនការ និងកត់ត្រាសកម្មភាព ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។ អ្នកមិនតម្រូវចាំបាច់ឱ្យប្រើឯកសារទាំងអស់នោះទេ ប៉ុន្តែកំណត់ត្រាការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវតែបញ្ចូលព័ត៌មានទាំងអស់ដែលមាននៅក្នុងបញ្ជីកត់ត្រាសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ឧទាហរណ៍៖ កស្តុតាងនៃឯកសារយោងរួមមាន៖

- ឈ្មោះ មុខតំណែង និងហត្ថលេខា របស់អ្នកគ្រប់គ្រង ឬអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលខ្លី។ (រយៈពេលពី ១ទៅ ៦ ម៉ោង) នៅក្នុងកន្លែងការងារ ។
- កម្មវិធី ឬវគ្គសិក្សាលើសពីមួយថ្ងៃដែលមានគោលបំណង និងគោលដៅសិក្សាមាតិកាច្បាស់លាស់ឈ្មោះ និងគុណវុឌ្ឍិរបស់អ្នកធ្វើបទបង្ហាញដែលមានបទពិសោធន៍ដែលផ្តល់ដោយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ ។

- វិញ្ញាបនបត្រនៃការចូលរួម ឬសម្រេចបាន
- លទ្ធផលនៃការវាយតម្លៃណាមួយដែលបានអនុវត្ត
- កំណត់ត្រាសង្ខេបពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តដោយខ្លួនឯង ដូចជា ការអានឯកសារវិទ្យាសាស្ត្រ ករណីសិក្សា ឬអត្ថបទទិនានុប្បវត្តិ ។

៩. អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់៖

ជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជាថាបានបំពេញតាមនិយាម ដែលតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាពដល់អ្នកប្រកបវិជ្ជាជីវៈថែទាំ ។ អង្គភាព និងដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ អាចផ្តល់នូវសកម្មភាពវិជ្ជាជីវៈជាក់លាក់ ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬទាំងពីរ ។

ការទទួលខុសត្រូវរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តរួមមាន៖

- មានការទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជាថាជាអ្នកផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ជើរតួនាទីជាអ្នកផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តគម្រូ និងសមរម្យ ហើយជាដៃគូរបស់អ្នកផ្តល់ការបណ្តុះបណ្តាល ដែលមិនបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា
- ប្រកាន់ខ្ជាប់តាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ស្វែងរកការគាំទ្រសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- បង្កើតសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបំពេញតាមនិយាមរបស់គណៈវិជ្ជាជីវៈ សម្រាប់ការផ្តល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ផ្តល់ និងវាយតម្លៃមាតិកានៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត
- បង្កើត ឬស្វែងរកធនធានបង្រៀនដែលពាក់ព័ន្ធ
- ផ្សព្វផ្សាយ និងផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាព
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ជាតិ ភូមិភាគ និងរាជធានី ខេត្ត
- ទំនាក់ទំនងជាមួយគណៈគិលានុបដ្ឋាកកម្ពុជានិង អ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីធ្វើការវាយតម្លៃលើតម្រូវការរបស់ការបណ្តុះបណ្តាល
- ចូលរួមក្នុងវេទិកាអ្នកផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- កាត់បន្ថយទំនាស់ផលប្រយោជន៍ឱ្យនៅទាបបំផុត ដែលទាក់ទងនឹងអ្នកគាំទ្រពាណិជ្ជកម្ម និងបង្ហាញពីទំនាស់ផលប្រយោជន៍ណាមួយប្រសិនបើមាន ។

គោលការណ៍ណែនាំដាច់ដោយឡែកមួយ សម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ណែនាំអំពីតួនាទីរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការទទួលស្គាល់ និងសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដើម្បីជាជំនួយដល់អ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់បំពេញយ៉ាងពេញលេញនូវលក្ខខណ្ឌតម្រូវអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដើម្បីបន្តអាជ្ញាបណ្ណប្រកបវិជ្ជា ជីវៈរបស់ពួកគេ ។

១០. គោលការណ៍បន្ថែមសម្រាប់ការអតិវឌ្ឍវិជ្ជាជីវៈបន្ត

ដោយអនុលោមតាមគោលការណ៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់ត្រូវស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈយ៉ាងតិច ៣ (បី)ខែ មុនពេលអាជ្ញាបណ្ណអស់សុពលភាព។ នៅពេលស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ អ្នកប្រកបវិជ្ជាជីវៈថែទាំត្រូវប្រកាស និងផ្តល់ឯកសារភ័ស្តុតាងដែលបង្ហាញថាសាមីខ្លួនបានអនុវត្តតាមនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ក្នុងករណីដែលអ្នកប្រកបវិជ្ជាជីវៈថែទាំមិនបានបំពេញពិន្ទុគ្រប់ចំនួនតាមលក្ខខណ្ឌគណៈគិលានុបដ្ឋាកកម្ពុជានឹងមិនបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំជូនឡើយ។

ការអនុលោមតាមនិយាម និងគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត គណៈគិលានុបដ្ឋាកកម្ពុជាអាចធ្វើសវនកម្ម បានគ្រប់ពេល ឬ នៅពេលទទួលបានបណ្តឹងដែលពាក់ព័ន្ធនឹងសម្បទា ឬកំហុសឆ្គងក្នុងការអ្នកប្រកបវិជ្ជាជីវៈថែទាំ។

*** គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះ ត្រូវបានបង្កើតឡើងដោយគណៈគិលានុបដ្ឋាកកម្ពុជាដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល និងនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់គណៈគិលានុបដ្ឋាកកម្ពុជា។

ខាក្យសព្ទ

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត សំដៅដល់ដំណើរការនៃការសិក្សាពេញមួយជីវិត ដែលមានគោលបំណងរក្សា និងលើកកម្ពស់នូវការអនុវត្តរបស់អ្នកប្រកបវិជ្ជាជីវៈថែទាំតាមរយៈការពង្រីកចំណេះដឹង (ការស្រាវជ្រាវជំនាញវិជ្ជាជីវៈ សមត្ថភាពវិជ្ជាជីវៈ) ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ។

ការប្រកបវិជ្ជាជីវៈ ក្នុងបរិបទនេះសំដៅដល់ រាល់តួនាទីដែលបុគ្គលម្នាក់ៗប្រើជំនាញនិងចំណេះដឹងជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ក្នុងវិជ្ជាជីវៈរបស់ពួកគេ។

ការប្រកបវិជ្ជាជីវៈ មិនសំដៅតែការផ្តល់សេវាព្យាបាល ថែទាំវេជ្ជសាស្ត្រ ជាមួយអតិថិជនដោយផ្ទាល់នោះទេ ដោយរាប់បញ្ចូលទាំងការងារគ្រប់គ្រងរដ្ឋបាល អប់រំ/បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់ប្រឹក្សា អភិវឌ្ឍគោលនយោបាយ ឬ បទប្បញ្ញត្តិ និងតួនាទីផ្សេងៗទៀត ដែលប៉ះពាល់ដល់សុវត្ថិភាព ប្រសិទ្ធភាពនៃការផ្តល់សេវាតាមរយៈវិជ្ជាជីវៈនោះ ទោះជាបានឬមិនបានទទួលកម្រៃក៏ដោយ ។

អ្នកវិជ្ជាជីវៈថែទាំ សំដៅដល់ គិលានុបដ្ឋាក ទន្តគិលានុបដ្ឋាក ដែលទទួលបានការចុះបញ្ជិកាជាមួយគណៈគិលានុបដ្ឋាកកម្ពុជា ។

អ្នកប្រកបវិជ្ជាជីវៈថែទាំ សំដៅដល់អ្នកវិជ្ជាជីវៈថែទាំ ដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ។

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈទទួលស្គាល់

គឺជាអង្គភាព ឬដៃគូជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដែលត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាវិជ្ជាជីវៈថាបានបំពេញតាមបទដ្ឋានដែលតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាពដល់អ្នកប្រកបវិជ្ជាជីវៈថែទាំ ។ អង្គភាព និងដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់អាចផ្តល់នូវសកម្មភាពវិជ្ជាជីវៈជាក់លាក់ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តឬទាំងពីរ។

ពិនិត្យឡើងវិញ៖

គោលការណ៍ណែនាំនេះ នឹងត្រូវពិនិត្យឡើងវិញដោយគណៈគិលានុបដ្ឋាកកម្ពុជាតាមភាពចាំបាច់ ។

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

គណៈគិលានុបដ្ឋាកកម្ពុជា

ប្រធាន

អនុបណ្ឌិត អ៊ុន សាន

ផែនការសិក្សាផ្ទាល់ខ្លួន សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

នាមត្រកូល: នាមខ្លួន:

លេខចុះបញ្ជិកា:

រដ្ឋនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តចាប់ពី: រហូតដល់:

កំណត់គោលដៅនៃការសិក្សារបស់អ្នក

អ្វីដែលខ្ញុំចង់រៀន?	អ្វីដែលខ្ញុំត្រូវធ្វើ?	អ្វីដែលជាការគាំទ្រ និងធនធានដែលខ្ញុំត្រូវការ?	តើខ្ញុំវាស់វែងភាពជោគជ័យ ឬលទ្ធផលនៃការសិក្សារបស់ខ្ញុំដោយរបៀបណា?	កាលបរិច្ឆេទគោលដៅសម្រាប់ពិនិត្យឡើងវិញ

កំណត់ត្រា សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត

នាមត្រកូល: នាមខ្លួន:

លេខចុះបញ្ជិកា:

រដ្ឋនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ចាប់ពី: រហូតដល់:

ពិព័ណ៌នា សកម្មភាព អភិវឌ្ឍវិជ្ជាជីវៈ បន្ត	ឈ្មោះអ្នកផ្តល់ អភិវឌ្ឍវិជ្ជាជីវៈ បន្ត	អាសយដ្ឋាននៃទី កន្លែង ផ្តល់វគ្គ	ចាប់ពី/រហូត ដល់ (ថ្ងៃ/ខែ/ឆ្នាំ)	ចំនួន ម៉ោង CPD	**វិញ្ញាបនប័ត្របញ្ចប់ការ** សិក្សា/ការចូលរួម ឬឈ្មោះ តួនាទី និងហត្ថលេខារបស់ អ្នកផ្តល់អភិវឌ្ឍវិជ្ជាជីវៈបន្ត

សូមរក្សាច្បាប់ចម្លងនៃកម្មវិធីទាំងអស់ វិញ្ញាបនប័ត្រនៃការចូលរួមឬការបញ្ចប់; ឯកសារនៃការវាយតម្លៃឬប្រតិចារឹកនៃការសិក្សា យ៉ាងតិចបំផុត ០៣ ឆ្នាំ

* សម្រាប់សកម្មភាព CPD តិចជាង 1 ថ្ងៃដែលពុំមានវិញ្ញាបនប័ត្រនៃការចូលរួមឬការបញ្ចប់ សូមស្នើសុំឈ្មោះ តួនាទីនិងហត្ថលេខារបស់អ្នកសម្រប សម្រួលនៃសកម្មភាព CPD នៅក្នុងកំណត់ត្រាសកម្មភាព CPD តែមួយ (សូមមើលឯកសារភ្ជាប់ C)

កំណត់ត្រា សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ពិព័ណ៌នា សកម្មភាព អភិវឌ្ឍវិជ្ជាជីវៈ បន្ត	ឈ្មោះអ្នកផ្តល់ អភិវឌ្ឍវិជ្ជាជីវៈ បន្ត	អាសយដ្ឋាននៃទី កន្លែង ផ្តល់វគ្គ	ចាប់ពី/រហូត ដល់ (ថ្ងៃ/ខែ/ឆ្នាំ)	ចំនួន ម៉ោង CPD	**វិញ្ញាបនប័ត្របញ្ចប់ការ សិក្សា/ការចូលរួម ឬឈ្មោះ តួនាទី និងហត្ថលេខារបស់ អ្នកផ្តល់អភិវឌ្ឍវិជ្ជាជីវៈបន្ត**

សូមរក្សាច្បាប់ចម្លងនៃកម្មវិធីទាំងអស់ វិញ្ញាបនប័ត្រនៃការចូលរួមឬការបញ្ចប់; ឯកសារនៃការវាយតម្លៃឬប្រតិចារឹកនៃការសិក្សា យ៉ាងតិចបំផុត ០៣ ឆ្នាំ

* សម្រាប់សកម្មភាព CPD តិចជាង 1 ថ្ងៃដែលពុំមានវិញ្ញាបនប័ត្រនៃការចូលរួមឬការបញ្ចប់ សូមស្នើសុំឈ្មោះ តួនាទីនិងហត្ថលេខារបស់អ្នកសម្រប សម្រួលនៃសកម្មភាព CPD នៅក្នុងកំណត់ត្រាសកម្មភាព CPD តែមួយ (សូមមើលឯកសារភ្ជាប់ C)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



គណៈគិលានុបដ្ឋាកកម្ពុជា

គោលការណ៍ណែនាំ
ស្តីពី
អត្តសាញ្ញាណប័ណ្ណនិងការបណ្តុះបណ្តាល
សម្រាប់ការអនុវត្តវិជ្ជាជីវៈបន្ត

ខែ វិច្ឆិកា ឆ្នាំ២០១៩

សេចក្តីផ្តើម

គណៈគិលានុបដ្ឋាកកម្ពុជាទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល និងកំណត់លក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់អ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់។

សេចក្តីសម្រេចរបស់គណៈគិលានុបដ្ឋាកកម្ពុជាសម្រាប់និយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត តម្រូវឱ្យអ្នកប្រកបវិជ្ជាជីវៈថែទាំបំពេញពិន្ទុអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ និងធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង សមត្ថភាពជំនាញថ្មីៗ ដើម្បីផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្របតាមអនុក្រឹត្យក្រមសីលធម៌វិជ្ជាជីវៈ និងច្បាប់ជូនដល់អ្នកជំងឺ អតិថិជន និងសហគមន៍។

គោលការណ៍ណែនាំរបស់គណៈគិលានុបដ្ឋាកកម្ពុជា ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត ផ្តល់ព័ត៌មានបន្ថែមអំពីលក្ខខណ្ឌនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តអប្បបរមា និងផ្តល់ព័ត៌មានអំពី តើអង្គភាព ឬដៃគូណា និងរបៀបណាដែលអ្នកប្រកបវិជ្ជាជីវៈថែទាំអាចបំពេញតាមតម្រូវការទាំងអស់នេះបាន។ សាលាកបត្រព័ត៌មានរបស់គណៈគិលានុបដ្ឋាកកម្ពុជាបំពេញបន្ថែមឱ្យគោលការណ៍ណែនាំនេះ និងផ្តល់ជាការឆ្លើយតបសម្រាប់សំណួរ ដែលអ្នកប្រកបវិជ្ជាជីវៈថែទាំចង់ដឹង និងសម្រាប់ជាឯកសារយោង។

គោលការណ៍ណែនាំស្តីពីអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ទាក់ទងអំពីតួនាទីការទទួលស្គាល់ព្រមទាំងសកម្មភាពរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាជំនួយដល់អ្នកប្រកបវិជ្ជាជីវៈថែទាំអាចបំពេញតាមលក្ខខណ្ឌអប្បបរមាសម្រាប់ ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលជាផ្នែកមួយនៃការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំដំបូង (អ្នកវិជ្ជាជីវៈសុខាភិបាលដែលបានបញ្ចប់ការសិក្សាលើសពី ៣ឆ្នាំ) ឬសុំឡើងវិញសម្រាប់បន្តការប្រកបវិជ្ជាជីវៈថែទាំ។

គោលការណ៍ណែនាំសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះសមស្របសម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ អ្នកវិជ្ជាជីវៈថែទាំ ភាគីពាក់ព័ន្ធ និងសាធារណជន។

១. ការប្រើប្រាស់គោលការណ៍ណែនាំសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គោលការណ៍ណែនាំនេះប្រើសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ទាំងជាតិ និងអន្តរជាតិ ដែលមានបំណងចង់ក្លាយជា អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលបានទទួលស្គាល់ក្នុងប្រទេសកម្ពុជា និង៖

- ផ្តល់សកម្មភាពបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជូនដល់អ្នកប្រកបវិជ្ជាជីវៈថែទាំ
- ទទួលបានចំនួនម៉ោងនៃការរៀនសកម្ម សម្រាប់សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានទទួលស្គាល់ និងផ្តល់ជាពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដោយគណៈគិលានុបដ្ឋាកកម្ពុជា ដូច្នេះអ្នកប្រកប

វិជ្ជាជីវៈថែទាំ អាចទទួលបាននៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សរុបចំនួន ៦០ (ហុកសិប)ពិន្ទុ សម្រាប់រយៈពេល៣(បី)ឆ្នាំ នៃវដ្តការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

២. និយមន័យ នៃអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា

គឺជាអង្គភាព ឬដៃគូជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជាថាបានបំពេញតាមបទដ្ឋានដែលតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តដែលមានគុណភាព ដល់អ្នកប្រកបវិជ្ជាជីវៈថែទាំ។ អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់អាចផ្តល់នូវសកម្មភាពវិជ្ជាជីវៈជាក់លាក់ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬទាំងពីរ។

៣. ការទទួលស្គាល់ អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តជាច្រើនក្នុងការផ្តល់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តដល់ អ្នកវិជ្ជាជីវៈថែទាំ និងអ្នកប្រកបវិជ្ជាជីវៈថែទាំ។ ស្ថាប័នទាំងនោះរួមមាន៖

- ក្រសួងសុខាភិបាល
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ: បាត់ដំបង ស្ទឹងត្រែង កំពង់ចាម និងកំពត
- វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ
- សាកលវិទ្យាល័យ ឯកជនដែលផ្តល់ការអប់រំផ្នែកសុខាភិបាល ហើយត្រូវបានអនុញ្ញាតដោយក្រសួងអប់រំយុវជននិងកីឡា និងក្រសួងសុខាភិបាល
- មន្ទីរពេទ្យរដ្ឋ និងឯកជន
- មន្ទីរសុខាភិបាលខេត្ត
- មន្ទីរពេទ្យបង្អែកខេត្ត
- សមាគមវិជ្ជាជីវៈសុខាភិបាល

ប្រសិនបើអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត មិនមាននៅក្នុងការបរិយាយខាងលើ ពួកគេត្រូវតែធ្វើការជាដៃគូជាមួយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ ឬធ្វើការស្នើសុំទៅគណៈគិលានុបដ្ឋាកកម្ពុជា ដើម្បីទទួលស្គាល់ថាជាអ្នកផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

គណៈគិលានុបដ្ឋាកកម្ពុជានឹងមិនទទួលស្គាល់នូវរាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តដែលបានរៀបចំឡើងដោយក្រុមហ៊ុនឱសថ ឬក្រុមហ៊ុនពាណិជ្ជកម្មតែឯងឡើយ។

***អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងអស់ ត្រូវតែផ្តល់ឯកសារពាក់ព័ន្ធដែលតម្រូវដោយគណៈគិលានុបដ្ឋាកកម្ពុជាជាមុន ដើម្បីស្នើសុំពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

៤. តួនាទីរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា

ការទទួលខុសត្រូវរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជាត្រូវ៖

- មានការទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា ថាជាអ្នកផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (សូមមើលចំណុចលេខ ៣ ខាងលើ)
- ដើរតួនាទីជាអ្នកផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តគំរូ និងសមរម្យ ហើយជាដៃគូរបស់អ្នកផ្តល់ការបណ្តុះបណ្តាល ដែលមិនបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា
- ប្រកាន់ខ្ជាប់តាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ស្វែងរកការគាំទ្រសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- បង្កើតសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលបំពេញតាមនិយាមរបស់គណៈគិលានុបដ្ឋាកកម្ពុជាសម្រាប់ការផ្តល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ផ្តល់ និងវាយតម្លៃមាតិកានៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត
- បង្កើត ឬស្វែងរកធនធានបង្រៀនដែលពាក់ព័ន្ធ
- ផ្សព្វផ្សាយ និងផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាព
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ជាតិ ភូមិភាគ និងរាជធានី ខេត្ត
- ទំនាក់ទំនងជាមួយគណៈគិលានុបដ្ឋាកកម្ពុជា និង អ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីធ្វើការវាយតម្លៃលើតម្រូវការរបស់ការបណ្តុះបណ្តាល
- ចូលរួមក្នុងវេទិកាអ្នកផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- កាត់បន្ថយទំនាស់ផលប្រយោជន៍ឱ្យនៅទាបបំផុតដែលទាក់ទងនឹងអ្នកគាំទ្រពាណិជ្ជកម្ម និងបង្ហាញពីទំនាស់ផលប្រយោជន៍ណាមួយប្រសិនបើមាន ។

៥. តួនាទីនៃសមាគមវិជ្ជាជីវៈសុខាភិបាល

សមាគមវិជ្ជាជីវៈសុខាភិបាលជាអង្គភាពដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាម ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបានបង្កើតឡើងជាតំណាងនៃក្រុម អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលជាក់លាក់មួយ ជាមួយនឹងអាណត្តិដើម្បីបំពេញការងារសម្រាប់ផលប្រយោជន៍វិជ្ជាជីវៈ និងផលប្រយោជន៍របស់សមាជិក។

សមាគមវិជ្ជាជីវៈសុខាភិបាល ជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា និងមានតួនាទីសំខាន់ជួយគណៈគិលានុបដ្ឋាកកម្ពុជារួមមាន៖

- ជម្រុញអ្នកវិជ្ជាជីវៈថែទាំ អ្នកប្រកបវិជ្ជាជីវៈថែទាំអនុវត្តសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- សម្របសម្រួលការផ្សព្វផ្សាយនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ គោលការណ៍ណែនាំ និងសាលាកបត្រព័ត៌មាន អំពីលក្ខខណ្ឌតម្រូវ ការអភិវឌ្ឍវិជ្ជាជីវៈបន្តថ្មីៗ របស់គណៈគិលានុបដ្ឋាកកម្ពុជាទៅដល់សមាជិកសមាជិការបស់សមាគម។
- ផ្តល់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ អ្នកប្រកបវិជ្ជាជីវៈថែទាំ ដែលត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា
- សម្របសម្រួលសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្នុងភាពជាដៃគូជាមួយគណៈគិលានុបដ្ឋាកកម្ពុជា

៦. លក្ខខណ្ឌសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលទទួលស្គាល់ ដោយគណៈគិលានុបដ្ឋាកកម្ពុជា

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជាត្រូវ៖

- ចាត់តាំងអ្នកទទួលខុសត្រូវឱ្យត្រួតពិនិត្យសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- រក្សាឯកសារសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានអនុវត្ត។ ឯកសារទាំងនេះ រួមមាន បញ្ជីឈ្មោះអ្នកចូលរួម ខ្លឹមសារបណ្តុះបណ្តាល និងរបាយការណ៍សកម្មភាព សម្រាប់រយៈពេលអប្បបរមា ៣ ឆ្នាំ ប៉ុន្តែមិនកំណត់ចំពោះកម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈបន្តនោះទេ ។
- ផ្តល់វិញ្ញាបនបត្រដល់អ្នកចូលរួមសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- បង្កើត រៀបចំ និងផ្តល់ឯកសារវាយតម្លៃ សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត តាមការស្នើសុំរបស់គណៈគិលានុបដ្ឋាកកម្ពុជា
- រក្សាទិន្នន័យបណ្តុះបណ្តាល និងចែករំលែកព័ត៌មានតាមការស្នើសុំពីគណៈគិលានុបដ្ឋាកកម្ពុជា
- ចូលរួមតាមដាន និងកែលម្អគុណភាពនៃសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ផ្អែកលើលទ្ធផលវាយតម្លៃ និងការផ្លាស់ប្តូរបែបបទនៃការផ្តល់ការថែទាំព្យាបាល ។

៧. លក្ខខណ្ឌសម្រាប់ការទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា ជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលមិនមានក្នុងបញ្ជីចំណុចលេខ ៣ ខាងលើ ត្រូវ៖

- ដាក់ពាក្យស្នើសុំដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យដើម្បីក្លាយជាអង្គភាពឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា។
- ស្នើសុំទៅគណៈគិលានុបដ្ឋាកកម្ពុជាដើម្បីទទួលស្គាល់ចំនួនម៉ោងរៀនសកម្ម និងពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់ផ្តល់ឱ្យអ្នកប្រកបវិជ្ជាជីវៈថែទាំ ។

គណៈគិលានុបដ្ឋាកកម្ពុជានឹងអនុវត្តលក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការទទួលស្គាល់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

៨. លក្ខណៈវិនិច្ឆ័យក្នុងការទទួលស្គាល់ជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា ត្រូវមានលក្ខណៈវិនិច្ឆ័យអប្បបរមាដូចខាងក្រោម ៖

- មានគ្រូបង្រៀន គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកសម្របសម្រួល ដែលមានសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់ពាក់ព័ន្ធនឹងខ្លឹមសារនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។
- ផ្តល់ភ័ស្តុតាងអំពីសមត្ថភាពនៃការបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធសមស្របក្នុងការផ្តល់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។
- បំពេញតាមលក្ខខណ្ឌរបស់គណៈគិលានុបដ្ឋាកកម្ពុជាសម្រាប់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។
- មានទីតាំងរូបវន្តនៅថ្នាក់ជាតិ ថ្នាក់តំបន់ និង ថ្នាក់ខេត្ត។
- មានហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និងឧបករណ៍សិក្សាសមស្រប និងពាក់ព័ន្ធ។
- ប្រើវិធីសាស្ត្រ និងឧបករណ៍វាយតម្លៃមានសុពលភាព អាចទុកចិត្តបាន ដែលផ្តល់ព័ត៌មានត្រឡប់ថាតើការសិក្សាបានសម្រេចគោលដៅដែរឬទេ?។
- ផ្តល់ឯកសារ និងព័ត៌មានពាក់ព័ន្ធអំពីការរៀបចំ និងខ្លឹមសារសម្រាប់វគ្គសិក្សា៖ ចំនួនម៉ោងរៀនសកម្ម ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់សិក្ខាកាម និងលទ្ធផលវាយតម្លៃ។
- អនុលោមតាមលក្ខខណ្ឌសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវសន្យាថាសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនោះមានគុណភាព ។

៩. និយាមសម្រាប់ការផ្តល់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដោយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ដើម្បីឱ្យសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត មានសិទ្ធិទទួលបានពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវបំពេញតាមនិយាមដែលបានបញ្ជាក់ខាងក្រោម៖

និយាមទី១

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវមានរយៈពេលបណ្តុះបណ្តាលយ៉ាងតិចមួយម៉ោង ដែលសិក្ខាកាមបានចូលរួមសកម្ម។

និយាមទី២

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវអនុវត្តតាមនិយាម និងគោលការណ៍ណែនាំដែលគណៈគិលានុបដ្ឋាកកម្ពុជាបានអនុម័តអំពី ការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់អ្នកវិជ្ជាជីវៈថែទាំ និងអ្នកប្រកបវិជ្ជាជីវៈថែទាំ ហើយគោលការណ៍ណែនាំទាំងនេះសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

និយាមទី៣

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវទទួលស្គាល់ក្នុងប្រទេសកម្ពុជា ឬក្នុងប្រទេសរបស់ខ្លួន។ ប្រសិនបើទទួលស្គាល់នៅក្រៅប្រទេសកម្ពុជា ស្ថាប័នទាំងនោះ ត្រូវតែជាដៃគូជាមួយ អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានទទួលស្គាល់ក្នុងប្រទេសកម្ពុជា ឬទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជាផ្ទាល់។

និយាមទី៤

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវផ្តល់ដោយគ្រូបង្រៀន គ្រូឧទ្ទេស គ្រូបង្គោល ឬអ្នកសម្របសម្រួល ដែលមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្របទៅនឹងប្រធានបទ ដែលគណៈគិលានុបដ្ឋាកកម្ពុជាអាចធ្វើការផ្ទៀងផ្ទាត់បាន។ បុគ្គលទាំងនេះត្រូវផ្តល់ការអប់រំដែលមានគុណភាពខ្ពស់ និងជ្រើសរើសប្រធានបទដែលមានបច្ចុប្បន្នភាព ព្រមទាំងប្រើវិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាពឱ្យបន្សុំទៅនឹងខ្លឹមសារនៃប្រធានបទកម្រិតនិងប្រភេទនៃអ្នកចូលរួមសិក្សា។

និយាមទី៥

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តត្រូវមានធនធាន(មនុស្ស សម្ភារៈ ថវិកា ។ល។)គ្រប់គ្រាន់ និងសមស្របក្នុងការផ្តល់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

និយាមទី៦

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវប្រើវិធីសាស្ត្រ និងឧបករណ៍វាយតម្លៃមានសុពលភាព អាចទុកចិត្តបាន ដែលផ្តល់ព័ត៌មានត្រឡប់ ថាតើការសិក្សាបានសម្រេចគោលដៅដែរឬទេ?

និយាមទី៧

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តត្រូវមាននីតិវិធី និងប្រព័ន្ធសមស្រប សម្រាប់ប្រមូលទិន្នន័យ ហើយធានាសុវត្ថិភាពនៃការរក្សាទុកឯកសារ កំណត់ត្រារបស់សិក្ខាកាម ដែលបានចូលរួមសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

និយាមទី៨

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវស្វែងយល់ពីតម្រូវការដើម្បីកាត់បន្ថយជម្លោះផលប្រយោជន៍នានាពាក់ព័ន្ធនឹងអ្នកគាំទ្រពាណិជ្ជកម្ម និងមានឆន្ទៈបង្ហាញរាល់ជម្លោះផលប្រយោជន៍ចំពោះសិក្ខាកាមនៅពេលចាប់ផ្តើមសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

១០. លក្ខខណ្ឌសម្រាប់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលស្នើ ឬច្រើនជាង ១ថ្ងៃ

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលពាក់ព័ន្ធនឹងវគ្គបណ្តុះបណ្តាលមានរយៈពេលមួយថ្ងៃ ឬលើសត្រូវមានឯកសារដែលបង្ហាញពី គោលបំណង និងគោលដៅ ជាមួយអ្នកជំនាញ អ្នកសម្របសម្រួល ឬ/និង អ្នកធ្វើបទបង្ហាញ ឬ/និងដោយរួមបញ្ចូលការវាយតម្លៃដែលបង្ហាញពីការអនុវត្តនូវចំណេះដឹង និងជំនាញថ្មីៗនៅក្នុងការប្រកបវិជ្ជាជីវៈ។

ឯកសារទាំងនេះត្រូវផ្តល់ឱ្យគណៈគិលានុបដ្ឋាកកម្ពុជា យ៉ាងហោចណាស់ ៣០ថ្ងៃនៃថ្ងៃធ្វើការ មុនពេលផ្តល់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់ធ្វើការពិនិត្យ និងផ្តល់ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់អន្តរវិជ្ជាជីវៈ អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលបានទទួលស្គាល់ តម្រូវឱ្យផ្តល់ឯកសារទៅឱ្យគណៈវិជ្ជាជីវៈនីមួយៗ សម្រាប់ផ្តល់ពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

១១. ប្រភេទនៃសកម្មភាព និងការផ្តល់ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាច្រើន ដែលត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា ដូចមាននៅក្នុងតារាងខាងក្រោមដើម្បីជាមគ្គុទ្ទេសក៍។ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តនីមួយៗ គឺអាស្រ័យលើចំនួនម៉ោងជាក់ស្តែងដែលអ្នកប្រកបវិជ្ជាជីវៈចៃទាំចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសិក្សា។ ពេលវេលាចំណាយសម្រាប់សកម្មភាពកម្មវិធីដូចជា ការចុះឈ្មោះ ការសម្រាកពិសារអាហារ សម្រន់ សុន្ទរកថា និងកម្មវិធីផ្សេងៗ មិនត្រូវបានទទួលស្គាល់ថាជាការរៀនសកម្ម និងមិនអាចចាត់ចូលជាពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តបានទេ។ ឧទាហរណ៍៖ សិក្ខាសាលាដែលមានរយៈពេល ១ ថ្ងៃ ឬ ៨ ម៉ោង ដែលក្នុងនោះរាប់បញ្ចូលទាំង ២ ម៉ោងនៃការពិសារអាហារ សម្រាកអាហារសម្រន់ និង ១ម៉ោងសម្រាប់សុន្ទរកថា នោះបាននំយថាសកម្មភាពរៀនសកម្មមានតែ ៥ ម៉ោងប៉ុណ្ណោះ ហើយក៏បាននំយថា ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសរុបសម្រាប់សិក្ខាសាលានេះ គឺ ៥ ពិន្ទុ ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តខ្លះ ដែលមាននៅក្នុងតារាងខាងក្រោម រួមបញ្ចូលចំនួនអតិបរមានៃពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលត្រូវបានផ្តល់ឱ្យ ដែលមិនគិតពីចំនួនម៉ោងសរុបនៃការរៀនសូត្រសកម្ម។
ឧទាហរណ៍៖ វគ្គបណ្តុះបណ្តាលរយៈពេល ៤ ថ្ងៃ ដែលមានការរៀនសូត្រសកម្មសរុប អាចដល់២៤ ម៉ោងស្មើនឹង ២៤ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ទោះយ៉ាងនេះក្តី ពិន្ទុអតិបរមានៃពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដែលមានរយៈពេលពី ១ថ្ងៃ ទៅ ២សប្តាហ៍ គឺ ១៥ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ដូច្នេះវគ្គបណ្តុះបណ្តាលរយៈពេល ៤ថ្ងៃ នឹងត្រូវបានគេឱ្យពិន្ទុចំនួនអតិបរមា១៥ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

នៅពេលបញ្ចប់ការសិក្សាដោយជោគជ័យ មានការវាយតម្លៃចំណេះដឹង (Post Test) ដែលជាផ្នែកនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាប់ជាផ្លូវការ ដោយមានកស្តុតាងបង្ហាញ នោះសិក្ខាកាមអាចទទួលបាន ២ ពិន្ទុបន្ថែមទៀត លើពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសរុប ។

តារាងទី១. សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការផ្តល់ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ល.រ	សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត	ចំនួនពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត (១ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត =១ ម៉ោង នៃការរៀនសកម្ម)	ចំនួនពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អតិបរមា
១	ការពិភាក្សាករណីសិក្សាជាក្រុម/ ចូលរួមការប្រជុំបច្ចេកទេស (កូឡូក)	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀន សកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
២	ការសិក្សាដោយខ្លួនឯង * (អានអត្ថបទទិនានុប្បវត្តិ នៅក្នុងទិនានុប្បវត្តិល្បីៗទាក់ទងនឹងសុខភាព ឬការបោះពុម្ពផ្សាយ តាមអ៊ីនធឺណិតទាក់ទងនឹងសុខភាព ឬ វេប៊ីណា (**Webinars**) ឬ វីដេអូទាក់ទងនឹងសុខភាព) * ត្រូវការកស្តុតាងជាលាយលក្ខណ៍អក្សរ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀន សកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ ពិន្ទុ
៣	សិក្ខាសាលាបណ្តុះបណ្តាល ដែលមានរយៈពេល ១ថ្ងៃ - ២សប្តាហ៍	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១៥ពិន្ទុ
៤	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល > ២សប្តាហ៍ ទៅ ៣ខែ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២៥ពិន្ទុ
៥	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល > ៣ខែ ទៅ ៦ខែ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ៣៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ៣៥ពិន្ទុ

៦	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល >៦ ទៅ ១២ខែ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ៤៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ៤៥ពិន្ទុ
៧	ចូលរួមការអប់រំនៅកន្លែងធ្វើការ វគ្គសិក្សាក្នុងពេលបំពេញការងារ(In-service training) ឬ កម្មវិធីអភិវឌ្ឍជំនាញ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
៨	ចូលរួមសន្និសីទក្នុងប្រទេសកម្ពុជា	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀន សកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
៩	ចូលរួមសន្និសីទ សន្និបាត មហាសន្និបាត ក្រៅប្រទេស	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២០ពិន្ទុ
១០	ស្រាវជ្រាវ រៀបចំ សម្រាប់ធ្វើបទបង្ហាញ នៅម៉ោងបង្រៀន ឬបទបង្ហាញក្នុងសន្និសីទជាតិ ឬអន្តរជាតិ (ដែលមិនមែនជាផ្នែកនៃការបង្រៀនដូចធម្មតា)	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងស្រាវជ្រាវ រៀបចំ ដើម្បីធ្វើបទបង្ហាញ រហូតដល់ អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១១	ចូលរួមជាសមាជិកក្នុងក្រុមស្រាវជ្រាវ ឬ ការងារគម្រោងទាក់ទងនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១២	ចូលរួមជាសមាជិកក្នុងក្រុមក្នុងការ បង្កើតគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំនានាទាក់ទងនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១៣	ស្រាវជ្រាវបន្ថែមនិងរៀបចំ ដើម្បីអភិវឌ្ឍ តួនាទីជាគ្រូណែនាំតាមមន្ទីរពេទ្យ គ្រូណែនាំ គ្រូបង្វឹកបុគ្គលិកឬនិស្សិត ហើយមានផែនការបណ្តុះបណ្តាលដែលមានឯកសារត្រឹមត្រូវ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១៤	ចូលរួមពិនិត្យនិងកែសម្រួលឯកសារអប់រំពាក់ព័ន្ធនឹងសុខាភិបាល អត្ថបទទិនានុប្បវត្តិ ជំពូកក្នុងសៀវភៅ ឬ ឯកសារសិក្សាស្រាវជ្រាវ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១៥ពិន្ទុ
១៥	ក្នុងនាមជាសហនិពន្ធ ចុះផ្សាយឯកសារ ឬរបាយការណ៍ ពាក់ព័ន្ធនឹងសុខាភិបាល	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១៥ពិន្ទុ
១៦	សរសេរអត្ថបទស្រាវជ្រាវ ជំពូកសៀវភៅ ឬរបាយការណ៍ក្នុងនាមជាអ្នកនិពន្ធទី១ ហើយបញ្ជូនដើម្បីចុះផ្សាយ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២០ពិន្ទុ

១៧	ចុះផ្សាយឯកសារ ជំពូកសៀវភៅ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខាភិបាល ក្នុងនាមជាអ្នកនិពន្ធទី១	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២០ពិន្ទុ
១៨	ជាប្រធានដឹកនាំក្នុងការ សិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២៥ពិន្ទុ
១៩	ជាប្រធានសម្របសម្រួលក្នុង ការធ្វើគម្រោងទាក់ទងនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២៥ពិន្ទុ
២០	រៀនវគ្គក្រោយឧត្តមសិក្សាដែលពាក់ព័ន្ធ នឹងជំនាញ នៅក្នុងប្រទេស ឬក្រៅប្រទេស ដែល ទទួលបានគុណវុឌ្ឍិជាផ្លូវការដូចជា បរិញ្ញាបត្រ សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬ បណ្ឌិត	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ៦០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ៦០ពិន្ទុ

នីតិវិធីនៃការផ្តល់សក្ខម្មភាព និងពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត នឹងត្រូវអនុវត្តជាចម្បងតាមរយៈ៖

- ការសិក្សាជាមួយគ្រូ ឬ អ្នកសម្របសម្រួលដោយផ្ទាល់ ឬការរៀនដោយខ្លួនឯង
- ការរៀន និងការបណ្តុះបណ្តាលពីចម្ងាយ(Online training)និងការសិក្សាជាក្រុម ដោយការធ្វើបទបង្ហាញតាមវីដេអូ

ចំពោះសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតាមរយៈការបណ្តុះបណ្តាលពីចម្ងាយ(Online training) ចាំបាច់ត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីសកម្មភាព (វិញ្ញាបនបត្របញ្ចប់ការសិក្សា និងការវាយតម្លៃ)។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតាមរយៈការបណ្តុះបណ្តាលពីចម្ងាយ(Online training) ដែលជាលក្ខណៈអន្តរជាតិអាចត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា នៅពេលដែលការបណ្តុះបណ្តាលទាំងនោះបានរៀបចំឡើងដោយអ្នកផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលមានកេរ្តិ៍ឈ្មោះ និងរួមបញ្ចូលការវាយតម្លៃជាឯកសារ

គណៈគិលានុបដ្ឋាកកម្ពុជា នឹងបង្កើតបញ្ជីសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត នៃការបណ្តុះបណ្តាលពីចម្ងាយ (Online training) ជាបន្តបន្ទាប់ទាំងក្នុងប្រទេសនិងអន្តរជាតិដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ ។

ចំនួនពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តការបណ្តុះបណ្តាលពីចម្ងាយ(Online training) គឺអាស្រ័យលើចំនួនម៉ោងដែលបានបញ្ជាក់ដោយអ្នកផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។ ពិន្ទុនេះអាចកើនឡើងទ្វេដង ចំពោះអ្នកប្រកបវិជ្ជាជីវៈថែទាំដែលជាជនជាតិខ្មែរក្នុងករណីសកម្មភាពសិក្សាតាមអនឡាញជាភាសាអង់គ្លេឬបារាំង ។

សម្រាប់អ្នកដែលបានបញ្ចប់ការវាយតម្លៃដោយជោគជ័យនៃការអភិវឌ្ឍវិជ្ជាបន្ត ហើយបានផ្តល់ឯកសារជាកស្តុតាងទៅគណៈគិលានុបដ្ឋាកកម្ពុជានឹងត្រូវបាន ២ពិន្ទុបន្ថែម ។
ឧទាហរណ៍៖ ការបញ្ចប់វគ្គសិក្សាជាភាសាអង់គ្លេសរយៈពេល ២ ម៉ោងតាមអនឡាញ បានពិន្ទុទ្វេដងស្មើនឹង ៤ ពិន្ទុហើយការបញ្ចប់ការវាយតម្លៃដោយជោគជ័យបានបន្ថែមចំនួនពិន្ទុ ២ទៀត ដូចនេះពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សរុបគឺ ៦ ពិន្ទុ ។

សកម្មភាពអន្តរវិជ្ជាជីវៈនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អន្តរវិជ្ជាជីវៈជាសកម្មភាពទាំងឡាយណាដែលផ្តោតលើនិយ័តកម្មវិជ្ជាជីវៈសុខាភិបាលចំនួនពីរ ឬច្រើន ហើយប្រធានបទទាំងនេះមានដូចជា៖

- ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- ជំងឺឆ្លង
- ជំងឺមិនឆ្លង
- ការស្រាវជ្រាវពាក់ព័ន្ធនឹងសុខាភិបាល
- សុខភាពបន្តពូជ

- សុខភាពមាតា និងទារក
- បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT)
- សុវត្ថិភាព និងសុខភាពការងារ
- ការគ្រប់គ្រងគ្រោះមហន្តរាយ
- ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ
- ការគ្រប់គ្រងគុណភាពសេវាសុខាភិបាល
- ការរៀននិងការបង្រៀន

ការផ្តល់ពិន្ទុចំពោះសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់អន្តរវិជ្ជាជីវៈ អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានទទួលស្គាល់តម្រូវឱ្យដាក់ឯកសារស្នើសុំ និងចំនួនម៉ោងនៃការរៀនសកម្មទៅគណៈគិលានុបដ្ឋាកកម្ពុជា ឱ្យបានមុន ៣០ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីទទួលបានការផ្តល់ពិន្ទុសម្រាប់អ្នកប្រកបវិជ្ជាជីវៈ។

១២. អនុលោមភាព

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានទទួលស្គាល់ទាំងអស់ត្រូវបង្ហាញនូវគុណនេយ្យភាព និងធានាសុវត្ថិភាពនៃសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្តប្រកបដោយគុណភាពដែលបង្កើនចំណេះដឹង និងសមត្ថភាពជំនាញ ព្រមទាំងការអនុវត្តរបស់ អ្នកប្រកបវិជ្ជាជីវៈថែទាំ ឈានដល់ភាពស្ទាត់ជំនាញតាមលក្ខខណ្ឌតម្រូវ។

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត តម្រូវឱ្យអនុវត្ត និងធានាអនុលោមតាមលក្ខខណ្ឌយ៉ាងពេញលេញដែលគណៈគិលានុបដ្ឋាកកម្ពុជាបានចែងក្នុងគោលការណ៍ណែនាំនេះ។
ចំណុចខាងក្រោមនេះចាត់ទុកថាមិនអនុលោមភាព៖

- មិនបានធ្វើតាមការណែនាំនូវចំណុចខ្វះខាតទាំងឡាយណា ដែលគណៈគិលានុបដ្ឋាកកម្ពុជាបានជូនដំណឹងឱ្យធ្វើការកែសម្រួលឡើងវិញក្នុងអំឡុងពេល៣ខែ។
- មិនបានបំពេញតាមលក្ខខណ្ឌ និងមិនអនុវត្តតួនាទីរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា។

នៅពេលដែលគណៈគិលានុបដ្ឋាកកម្ពុជាបានរកឃើញថា អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ណាមួយដែលបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា មិនអនុលោមតាមនិយាមនិងលក្ខខណ្ឌនៃកម្មវិធីបណ្តុះបណ្តាលដែលមានគុណភាព នោះគណៈគិលានុបដ្ឋាកកម្ពុជានឹងដាក់កំហិតមួយចំនួនលើអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តនោះ ដើម្បីឱ្យអនុវត្តតាមក្នុងរយៈពេលជាក់លាក់ណាមួយ ឬលុបចេញពីបញ្ជីរបស់ គណៈគិលានុបដ្ឋាកកម្ពុជារហូតដល់មានការកែតម្រូវ។

គោលការណ៍ណែនាំសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តត្រូវបានបង្កើតឡើងដោយគណៈគិលានុបដ្ឋាកកម្ពុជាសម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដោយអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល និងនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់គណៈគិលានុបដ្ឋាកកម្ពុជា (ខែ វិច្ឆិកា ឆ្នាំ២០១៩)

គោលការណ៍ណែនាំនេះ បំពេញបន្ថែមលើគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (ខែវិច្ឆិកាឆ្នាំ ២០១៩)

ន័យសព្ទ

ការរៀន "សកម្ម" គឺពាក់ព័ន្ធទៅនឹងពេលវេលា ម៉ោងជាក់ស្តែង ដែលអ្នកប្រកបវិជ្ជាជីវៈបានចំណាយពេលផ្តោតទៅសកម្មភាពរៀន ដើម្បីរក្សាសមត្ថភាពនិងអភិវឌ្ឍវិជ្ជាជីវៈ។

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត សំដៅដល់ដំណើរការនៃការសិក្សាពេញមួយជីវិត ដែលមានគោលបំណងរក្សានិងលើកកម្ពស់នូវការអនុវត្តរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលតាមរយៈការពង្រីកចំណេះដឹង (ការស្រាវជ្រាវ ជំនាញវិជ្ជាជីវៈ សមត្ថភាពវិជ្ជាជីវៈ) ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ។

ការប្រកបវិជ្ជាជីវៈ ក្នុងបរិបទនេះសំដៅដល់ រាល់តួនាទីដែលបុគ្គលម្នាក់ៗប្រើជំនាញនិងចំណេះដឹងជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ក្នុងវិជ្ជាជីវៈរបស់ពួកគេ។

ការប្រកបវិជ្ជាជីវៈ មិនសំដៅតែការផ្តល់សេវាព្យាបាល ថែទាំវេជ្ជសាស្ត្រ ជាមួយអតិថិជនដោយផ្ទាល់នោះទេ ដោយរាប់បញ្ចូលទាំងការងារគ្រប់គ្រងរដ្ឋបាល អប់រំ/បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់ប្រឹក្សា អភិវឌ្ឍគោលនយោបាយ ឬ បទប្បញ្ញត្តិ និងតួនាទីផ្សេងៗទៀត ដែលប៉ះពាល់ដល់សុវត្ថិភាព ប្រសិទ្ធភាពនៃការផ្តល់សេវាតាមរយៈវិជ្ជាជីវៈនោះ ទោះជាបានឬមិនបានទទួលកម្រៃក៏ដោយ ។

អ្នកវិជ្ជាជីវៈថែទាំ សំដៅដល់ គិលានុបដ្ឋាក ទន្តគិលានុបដ្ឋាក ដែលទទួលបានការចុះបញ្ជីកាជាមួយគណៈគិលានុបដ្ឋាកកម្ពុជា ។

អ្នកប្រកបវិជ្ជាជីវៈថែទាំ សំដៅដល់អ្នកវិជ្ជាជីវៈថែទាំ ដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ។

អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ គឺជាអង្គភាព ឬដៃគូជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាវិជ្ជាជីវៈថាបានបំពេញតាមបទដ្ឋានដែលតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាពដល់អ្នកប្រកបវិជ្ជាជីវៈថែទាំ ។ អង្គភាព និងដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការ**អភិវឌ្ឍវិជ្ជាជីវៈបន្ត** ដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ អាចផ្តល់នូវសកម្មភាពវិជ្ជាជីវៈជាក់លាក់ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តឬទាំងពីរ។

គោលការណ៍ណែនាំនេះនឹងត្រូវពិនិត្យនិងកែសម្រួលដោយគណៈគិលានុបដ្ឋាកកម្ពុជាតាមភាពចាំបាច់។

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

គណៈគិលានុបដ្ឋាកកម្ពុជា

ប្រធាន



អនុបណ្ឌិត អ៊ុន សាន

	គណៈគិលានុបដ្ឋាកជាតិកម្ពុជា
	ពាក្យស្នើសុំសម្រាប់ការអនុម័តផ្តល់ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត [សម្រាប់កម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានរយៈពេល៨ម៉ោងឬលើស (១ថ្ងៃ) នៃការរៀន "សកម្ម"]

ផ្នែក ១. ព័ត៌មានទូទៅ	
ឈ្មោះអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈគិលានុបដ្ឋាកទទួលស្គាល់៖	
ឈ្មោះដៃគូអ្នកផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត៖	
ឈ្មោះអ្នកទំនាក់ទំនង៖	តួនាទី៖
លេខទូរស័ព្ទ៖	អ៊ីម៉ែល៖
កាលបរិច្ឆេទដាក់ពាក្យស្នើសុំ៖	
កម្មវិធីស្នើសុំ៖ ☐ Seminar ☐ សិក្ខាសាលា ☐ វគ្គខ្លី (short course) ☐ ការសិក្សាក្រោយឧត្តម ☐ ផ្សេងៗ_____	
ចំណងជើងកម្មវិធី៖	
កាលបរិច្ឆេទដែលត្រូវផ្តល់ជូន៖	រយៈពេលនៃកម្មវិធីការរៀនសកម្ម គិតជាម៉ោង៖
ទីកន្លែង៖	ចំនួនដងនៃកម្មវិធី៖
ពណ៌នាកម្មវិធី៖	

គោលបំណងនិងគោលដៅនៃកម្មវិធី៖

អ្នកចូលរួមគោលដៅ៖	ចំនួនអ្នកចូលរួមដែលរំពឹងទុក៖

ផ្នែក ២៖ ការទទួលស្គាល់

ខ្ញុំសូមអះអាងថាព័ត៌មានដែលបានរៀបរាប់ក្នុងពាក្យសុំខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។ ខ្ញុំផ្តល់សិទ្ធិឱ្យគណៈគិលានុបដ្ឋាកកម្ពុជាស៊ើបអង្កេតបន្ថែមទៀតចំពោះភាពត្រឹមត្រូវនៃឯកសារ ដែលបានបង្ហាញទាំងអស់។

_____

ហត្ថលេខា

_____

ឈ្មោះ

_____

តួនាទី

_____

កាលបរិច្ឆេទ

ផ្នែក ៣. សកម្មភាពដែលបានអនុវត្ត

សមាជិកគណៈ៖ ដំណើរការដោយ៖_____ កាលបរិច្ឆេទ៖_____	**សមាជិកគណៈដែលបានចាត់តាំង (Designated Council Member) ៖** **ពិនិត្យដោយ៖**_____ កាលបរិច្ឆេទ៖_____

<u>សកម្មភាពចាត់ចែងដោយគណៈ</u>

☐ អនុម័តសម្រាប់ ____ ពិន្ទុ CPD

☐ មិនអនុម័ត

មូលហេតុ: _____

_____

☐ សេចក្តីសម្រេចពន្យាពេលអនុលោម រហូតដល់តម្រូវការត្រូវបានបំពេញ

_____

_____

_____

ប្រធានគណៈ:

_____ _____

សមាជិកគណៈ: *សមាជិកគណៈ:*

កាលបរិច្ឆេទ_____

ដំណើរការសម្រាប់ការអនុម័តពិន្ទុCPD និងកម្មវិធី CPD
បញ្ជីត្រួតពិនិត្យនៃតម្រូវការ
ឯកសារពាក់ព័ន្ធ
[ ] គោលបំណងកម្មវិធីជាក់លាក់ដែលមានចែងពីសមត្ថភាពដែលនឹងទទួលបានពីកម្មវិធី [ ] កម្មវិធីដែលបង្ហាញពីប្រធានបទនិងរយៈពេលនៃប្រធានបទ [ ] ការវាយតម្លៃកម្មវិធី [ ] ឧបករណ៍វាយតម្លៃជាក់លាក់ចំពោះគោលបំណងកម្មវិធី [ ] ប្រវត្តិរូបសង្ខេបអ្នកធ្វើបទបង្ហាញសម្រាប់កម្មវិធីដែលបានដាក់ពាក្យស្នើសុំ ដែលបង្ហាញពីជំនាញក្នុងប្រធានបទ គុណវុឌ្ឍិនិងកន្លែងសមស្រប ការចុះឈ្មោះ និងអាជ្ញាបណ្ណដើម្បីអនុវត្តជាមួយគណៈគិលានុបដ្ឋាកកម្ពុជា [ ] ភស្តុតាងដែលបង្ហាញថាកម្មវិធីនេះត្រូវបានបង្កើតឡើងនិង/ឬអនុម័តដោយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់
ចំណាំ: 1. ពាក្យស្នើសុំគួរតែដាក់ជូនគណៈគិលានុបដ្ឋាកកម្ពុជាមិនអោយតិចជាង 30 ថ្ងៃនៃថ្ងៃធ្វើការ មុនពេលផ្តល់សកម្មភាពវិជ្ជាជីវៈបន្ត 2. រយៈពេលសម្រាប់ដំណើរការពាក្យស្នើសុំពេញលេញគឺ ៣០ ថ្ងៃនៃថ្ងៃធ្វើការ 3. ប្រសិនបើមានតំរូវការបន្ថែម / ចាំបាច់ រយៈពេល ១៥ ថ្ងៃបន្ថែមនឹងផ្តល់ជូន។ ការខកខានមិនបានអនុវត្តអោយទាន់ពេលចាត់ទុកថាជាការបោះបង់ចោលពាក្យស្នើសុំ

គណៈគិលានុបដ្ឋាកជាតិកម្ពុជា

ពាក្យស្នើសុំទទួលស្គាល់

ជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

☐ ថ្មី ☐ ការបន្តជាថ្មី លេខនៃការទទួលស្គាល់. _____

កាលបរិច្ឆេទផុតកំណត់ _____

ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន/ព័ត៌មានពីស្ថាប័ន	
ឈ្មោះអ្នកផ្តល់វគ្គបណ្តុះបណ្តាល:	
ប្រភេទអ្នកផ្តល់ CPD: ☐ លក្ខណៈបុគ្គល / ក្រុមហ៊ុនមានលក្ខណៈបុគ្គល ☐ ក្រុមហ៊ុន/ដៃគូ/សាជីវកម្ម ☐ ស្ថាប័នរដ្ឋាភិបាល/ក្នាក់ងារ	
អាសយដ្ឋាន:	
លេខទូរស័ព្ទ:	Fax No.:
អ៊ីម៉ែល:	គេហទំព័រ:
ឈ្មោះអ្នកទំនាក់ទំនង:	តួនាទី:
លេខទូរស័ព្ទអ្នកទំនាក់ទំនង:	អ៊ីម៉ែល:

ផ្នែកទី២ ការទទួលស្គាល់

ខ្ញុំសូមបញ្ជាក់ថាព័ត៌មានដែលផ្តល់ជូនក្នុងពាក្យស្នើសុំនេះគឺពិត និងត្រឹមត្រូវទៅតាមចំណេះដឹង និងជំនឿរបស់ខ្ញុំ។ខ្ញុំផ្តល់សិទ្ធិអោយគណៈគិលានុបដ្ឋាកកម្ពុជាក្នុងការស៊ើបអង្កេតពីភាពត្រឹមត្រូវនៃឯកសារទាំងអស់ដែលបានដាក់ជូន។

_____

ហត្ថលេខា

_____

ឈ្មោះ

_____

តួនាទី

_____

កាលបរិច្ឆេទ

ផ្នែកទី៣ សកម្មភាពដែលបានចាត់ចែង	
គណៈគិលានុបដ្ឋាកកម្មជា ដំណើរការដោយ: _____ កាលបរិច្ឆេទ: _____	**សមាជិក**គណៈគិលានុបដ្ឋាកកម្មជា**ដែលបានចាត់តាំង**: ពិនិត្យដោយ: _____ កាលបរិច្ឆេទ: _____

<u>សកម្មភាពដែលបានចាត់ចែងដោយគណៈ:</u>

☐ **អនុម័ត** ទទួលស្គាល់ជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត លេខ. _____

☐ **មិនអនុម័ត**

មូលហេតុ: _____

_____

☐ *សម្រេចពន្យាការអនុលោមរហូតដល់តម្រូវការត្រូវបានបំពេញ*

_____

_____

_____

ប្រធានគណៈ:

_____

សមាជិកគណៈ: *សមាជិកគណៈ:*

*កាលបរិច្ឆេទ*_____

ដំណើរការក្នុងការទទួលស្គាល់ជា**អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត** (ក្នុងប្រទេស)
ជំហានទី ១. ទាញយកពាក្យស្នើសុំពី Website របស់គណៈគិលានុបដ្ឋាកកម្ពុជា (http://cambodiancouncilofnurse.com/kh/). ជំហានទី ២. បំពេញពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធចាំបាច់ (សូមផ្តល់ ឯកសារថតចម្លង១ច្បាប់នៃឯកសារទាំងអស់) ជំហានទី ៣. បង់ថ្លៃទៅអោយគណៈគិលានុបដ្ឋាកកម្ពុជា (ជាសាច់ប្រាក់ វេរតាមធនាគា..) នូវចំនួនទឹកប្រាក់ (..... រៀល) ជំហានទី ៤. ដាក់ពាក្យស្នើសុំដែលបំពេញរួច និងឯកសារពាក់ព័ន្ធចាំបាច់ និងថតចម្លង វិក្កយបត្រជូនគណៈគិលានុបដ្ឋាកកម្ពុជាដើម្បីធ្វើការវាយតម្លៃ។

បញ្ជីត្រួតពិនិត្យនៃតម្រូវការ

ឯកសារពាក់ព័ន្ធ

លក្ខណៈបុគ្គល/ក្រុមហ៊ុនមានលក្ខណបុគ្គល [ ] ប្រវត្តិរូបសង្ខេបត្រូវបញ្ចូល៖ ការអប់រំដែលពាក់ព័ន្ធ ស្ថានភាពការងារបច្ចុប្បន្ន វិជ្ជាជីវៈ ការប្រកបការងារដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈនិងចំនួនឆ្នាំក្នុងការប្រកបការងារដែលពាក់ព័ន្ធវិជ្ជាជីវៈ [ ] លេខចុះបញ្ជីកានិងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈដែលមានសុពលភាព (បើពាក់ព័ន្ធ) [ ] ព័ត៌មានពីក្រុមហ៊ុនត្រូវមានបញ្ចូល បេសកកម្ម ទស្សនវិស័យ គុណតម្លៃ និងបញ្ជីវគ្គបណ្តុះបណ្តាលដែលបានរៀបចំពីមុន [ ] បញ្ជី និងរូបភាពនៃឧបករណ៍ សម្ភារៈបង្រៀន និងទីកន្លែងបង្រៀន [ ] Instructional Design* (អោយជាឧទាហរណ៍មួយ) [ ] ផែនការប្រចាំឆ្នាំ នៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈដែលបានស្នើសុំ [ ] លិខិតទទួលស្គាល់ពីការអប់រំវិជ្ជាជីវៈសុខាភិបាល ឬ CPD ដែលទទួលស្គាល់ដោយអាជ្ញាធរវិជ្ជាជីវៈសុខាភិបាលក្នុងប្រទេស ឬ អន្តរជាតិ ** Instructional Design មានកំណត់ពីតម្រូវការនៃអ្នកចូលរួមរៀន កំណត់ពីគោលដៅ និងគោលបំណង ការបង្កើត និងផែនការនៃការប៉ាន់ប្រមាណ និង ការរៀបចំផែនការបង្រៀន និងការកំណត់សកម្មភាពនៃការរៀន ដើម្បីធានានូវគុណភាពនៃការណែនាំ។*	ក្រុមហ៊ុន /ការធ្វើការជាដៃគូ / ការសហការ [ ] ព័ត៌មានរបស់ក្រុមហ៊ុនត្រូវបញ្ចូលបេសកកម្ម ទស្សនវិស័យ គុណតម្លៃ និងបញ្ជីវគ្គបណ្តុះបណ្តាលដែលបានរៀបចំពីមុន [ ] បញ្ជីបុគ្គលិកនិង អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈដែលមានសុពលភាពក្នុងការប្រកបវិជ្ជាជីវៈ (បើពាក់ព័ន្ធ) [ ] បញ្ជី និងរូបភាពនៃឧបករណ៍ សម្ភារៈបង្រៀន និងទីកន្លែងបង្រៀន [ ] Instructional Design* (អោយជាឧទាហរណ៍មួយ) [ ] ផែនការប្រចាំឆ្នាំ នៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈដែលបានស្នើសុំ [ ] លិខិតក្រុមហ៊ុនដែលចាត់តាំងអោយបុគ្គលិកចាត់ចែង សកម្មភាព អភិវឌ្ឍវិជ្ជាជីវៈ [ ] លិខិតបញ្ជាក់ នៃការចុះបញ្ជី និងមាត្រាដែលចែងពីការសហកា ឬភាពជាដៃគូ នៃឯកសារតាមផ្លូវច្បាប់របស់ក្រុមហ៊ុន (ច្បាប់ឋិតចម្លងដែលបានផ្ទៀងផ្ទាត់) [ ] លិខិតទទួលស្គាល់ពីការអប់រំវិជ្ជាជីវៈសុខាភិបាល ឬ CPD ដែលទទួលស្គាល់ដោយអាជ្ញាធរវិជ្ជាជីវៈសុខាភិបាលក្នុងប្រទេស ឬ អន្តរជាតិ ** Instructional Design មានកំណត់ពីតម្រូវការនៃអ្នកចូលរួមរៀន កំណត់ពីគោលដៅ និងគោលបំណង ការបង្កើត និងផែនការនៃការប៉ាន់ប្រមាណ និង ការរៀបចំផែនការបង្រៀន និងការកំណត់សកម្មភាពនៃការរៀន ដើម្បីធានានូវគុណភាពនៃការណែនាំ។*	ស្ថាប័នរដ្ឋាភិបាល/ភ្នាក់ងារ [ ] ឋិតចម្លងឯកសារផ្លូវច្បាប់ ឬ លក្ខន្តិក:នៃការបង្កើតវិទ្យាស្ថាន/ភ្នាក់ងារ [ ] Instructional Design * (អោយជាឧទាហរណ៍មួយ) [ ] ផែនការប្រចាំឆ្នាំ នៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ ដែលបានស្នើសុំ [ ] លិខិតចាត់តាំង ឬឯកសារផ្សេងដែលមានតម្លៃស្មើពីថ្នាក់ដឹកនាំស្ថាប័ន ចាត់តាំងបុគ្គលិករបស់ខ្លួនក្នុងការចាត់ចែងសកម្មភាព អភិវឌ្ឍវិជ្ជាជីវៈ [ ] លិខិតទទួលស្គាល់ពីការអប់រំវិជ្ជាជីវៈសុខាភិបាល ឬ CPD ដែលទទួលស្គាល់ដោយអាជ្ញាធរវិជ្ជាជីវៈសុខាភិបាលក្នុងប្រទេស ឬ អន្តរជាតិ ** Instructional Design មានកំណត់ពីតម្រូវការនៃអ្នកចូលរួមរៀន កំណត់ពីគោលដៅ និងគោលបំណង ការបង្កើត និងផែនការនៃការប៉ាន់ប្រមាណ និង ការរៀបចំផែនការបង្រៀន និងការកំណត់សកម្មភាពនៃការរៀន ដើម្បីធានានូវគុណភាពនៃការណែនាំ។*

ការបន្តជាថ្មី

[ ] របាយការណ៍សង្ខេបដែលមានបញ្ចូលការវាយតម្លៃកម្មវិធីសម្រាប់ ០៣ ឆ្នាំកន្លងមក
[ ] បញ្ជី និងរូបភាពនៃឧបករណ៍សម្រាប់បណ្តុះបណ្តាល និងទីកន្លែងសម្រាប់បណ្តុះបណ្តាល
[ ] ផែនការប្រចាំឆ្នាំ នៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ ដែលបានស្នើសុំ
[ ] ព័ត៌មានទូទៅសម្រាប់ការសហការ ឬ ភាពជាដៃគូ
[ ] វិសោធនកម្មស្តីពីការសហការ ឬភាពជាដៃគូ ច្បាប់ ឬ លក្ខខន្តិក: ប្រសិនបើមានការកែប្រែ

[ ] លិខិតចាត់តាំង ឬឯកសារផ្សេងដែលមានតម្លៃស្មើពីថ្នាក់ដឹកនាំស្ថាប័ន ចាត់តាំងបុគ្គលិករបស់ខ្លួនក្នុងការចាត់ចែង សកម្មភាព CPD ប្រសិនបើមានការកែប្រែ

ចំណាំ:

4. អ្នកតំណាងក្នុងការបំពេញពាក្យស្នើសុំទទួលស្គាល់ជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងស្នើសុំលិខិតបញ្ជាក់ការទទួលស្គាល់ជំនួសអ្នកស្នើសុំ ត្រូវបង្ហាញលិខិតក្នុងការផ្តល់សិទ្ធិ/អនុញ្ញាត និងអត្តសញ្ញាណបណ្ណដែលមានសុពលភាព នៃអ្នកអនុញ្ញាត និងអ្នកតំណាង។
5. រយៈពេលនៃដំណើរការពាក្យសុំពេញលេញគឺ ៦០ថ្ងៃ
6. ប្រសិនមានតម្រូវការបន្ថែមបើចាំបាច់ រយៈពេល១៥ថ្ងៃ នឹងត្រូវផ្តល់ជូន។ ការខកខានមិនបានបំពេញនូវតម្រូវការតាមពេលវេលាដែលបានផ្តល់ជូន ត្រូវចាត់ទុកថាការស្នើសុំត្រូវបានបោះបង់ ថ្លៃដែលបានបង់អោយគណៈគិលានុបដ្ឋាកកម្ពុជា នឹងមិនបង្វិលជូនទៅអ្នកស្នើសុំវិញឡើយ
7. មាត្រាដែលពាក់ព័ន្ធនឹងការសហការ/ភាពជាដៃគូ គួរបញ្ចូលជាផ្នែកមួយនៃគោលបំណងនៃការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ វិជ្ជាជីវៈសុខាភិបាល ឬក្នុងករណីការធ្វើពាណិជ្ជកម្ម ឧស្សាហកម្ម ផ្តល់វគ្គបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ នៃវិជ្ជាជីវៈផ្ទាល់ខ្លួន

សាលាកប័ត្រព័ត៌មាន

គិលានុបដ្ឋាក គិលានុបដ្ឋាកយិកា

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ខែ វិច្ឆិកា ឆ្នាំ២០១៩

សេចក្តីផ្តើម

គណៈគិលានុបដ្ឋាកកម្ពុជាទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល និងកំណត់និយាមអប្បបរមាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលត្រូវអនុវត្តដោយអ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់។

សេចក្តីសម្រេចរបស់គណៈគិលានុបដ្ឋាកកម្ពុជាលើនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត គឺតម្រូវឱ្យអ្នកប្រកបវិជ្ជាជីវៈថែទាំបំពេញចំនួនម៉ោងអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ពាក់ព័ន្ធនឹងវិជ្ជាជីវៈថែទាំ ព្រមទាំងបង្កើនចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈ របស់ពួកគេ ក្នុងការផ្តល់សេវាសុខាភិបាល ទៅដល់អ្នកជំងឺ ឬអតិថិជនស្របតាមក្រមសីលធម៌ បទដ្ឋាន ច្បាប់ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ។

គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់គណៈគិលានុបដ្ឋាកកម្ពុជាផ្តល់នូវព័ត៌មានបន្ថែមទៅលើនិយាមអប្បបរមា សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់គណៈគិលានុបដ្ឋាកកម្ពុជា និងបង្ហាញពីរបៀបដែលអ្នកប្រកបវិជ្ជាជីវៈថែទាំអាចបំពេញតាមលក្ខខណ្ឌទាំងអស់នេះបាន ។ ឯកសារនេះបំពេញបន្ថែមទៅលើគោលការណ៍សម្រាប់ អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាល អំពីតួនាទី ការទទួលស្គាល់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាល និងសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដើម្បីជួយអ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់ដើម្បីបំពេញនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

សាលាកបត្រព័ត៌មាននេះ ពាក់ព័ន្ធទៅនឹងអ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់ ដែលត្រូវតែបំពេញតាមនិយាមអប្បបរមាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលជាលក្ខខណ្ឌដើម្បីបន្តអាជ្ញាបណ្ណ និងផ្តល់ជាចំណុចគន្លឹះ

សម្រាប់ជាឯកសារយោងដ៏ងាយស្រួល ។ វាសមស្របសម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំអ្នកវិជ្ជាជីវៈថែទាំដែលបានចុះបញ្ជិកា និស្សិតសុខាភិបាល អ្នកពាក់ព័ន្ធ និងសាធារណជន។

១. តើការអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬ CPD គឺជាអ្វី?

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) សំដៅដល់ដំណើរការនៃការសិក្សាពេញមួយជីវិត ដែលមានគោលបំណងរក្សា និងលើកកម្ពស់នូវការអនុវត្តរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលតាមរយៈការពង្រីកចំណេះដឹង (ការស្រាវជ្រាវ ជំនាញវិជ្ជាជីវៈ សមត្ថភាពវិជ្ជាជីវៈ) ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ។

២. ហេតុអ្វីបានជាខ្ញុំត្រូវការ ការអភិវឌ្ឍវិជ្ជាជីវៈបន្ត?

នៅក្នុងបរិបទនៃការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកបច្ចេកវិទ្យា បែបបទនៃការថែទាំព្យាបាល និងឱសថ ការរំពឹងទុករបស់សាធារណជនកាន់តែកើនឡើង និងភាពចាំបាច់សម្រាប់គុណភាពនៃការថែទាំ ក៏ដូចជាគណនេយ្យភាពកាន់តែប្រសើរ ការអភិវឌ្ឍវិជ្ជាជីវៈបន្តត្រូវបានគេទទួលស្គាល់ថាជាមធ្យោបាយដ៏មានសារសំខាន់ ដែលអ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់អាចរក្សាបាននូវសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន ។

៣. តើការអភិវឌ្ឍវិជ្ជាជីវៈបន្ត មានអត្ថប្រយោជន៍អ្វីខ្លះសម្រាប់ខ្ញុំ?

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត អាចជួយអ្នកធ្វើបច្ចុប្បន្នភាពជាប្រចាំនូវអ្វីដែលបានរៀនតាំងពីការបណ្តុះបណ្តាលមូលដ្ឋាន និងឆ្លុះបញ្ចាំងការផ្លាស់ប្តូរក្នុងការប្រកបវិជ្ជាជីវៈថែទាំ ដើម្បីធានាថា អ្នកផ្តល់ការថែទាំព្យាបាលប្រកបដោយសុវត្ថិភាព គុណភាព និងប្រើចំណេះដឹងថ្មីៗ ទៅកាន់អ្នកជំងឺ អតិថិជន ឬសហគមន៍របស់អ្នក។ កស្តុតាងការស្រាវជ្រាវបានបង្ហាញថា ក្នុងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាលមូលដ្ឋាន ចំណេះដឹងដែលបានទទួលក្លាយជាចំណេះដឹងហួសសម័យ ហេតុដូច្នេះហើយបើមិនបានអនុវត្ត ការអភិវឌ្ឍវិជ្ជាជីវៈបន្តទេនោះ ការប្រកបវិជ្ជាជីវៈនឹងអនុវត្តមិនបានល្អ ហើយអាចបង្កឱ្យមានហានិភ័យ ខ្ពស់ដល់អ្នកជំងឺ អតិថិជននិងសហគមន៍ (ឧ. ជំងឺ និងស្លាប់) ទៀតផង។ ការអភិវឌ្ឍវិជ្ជាជីវៈបន្ត មិនត្រឹមតែជាការធានាសមត្ថភាពរបស់អ្នកប្រកបវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសូចនាករគន្លឹះសម្រាប់ធានាគុណភាព នៃការថែទាំព្យាបាលទៀតផង ។

ការអភិវឌ្ឍវិជ្ជាជីវៈបន្តក៏អាចជួយអ្នកផងដែរ ក្នុងការព្យាករណ៍ និងឆ្លើយតបប្រកបដោយភាពវិជ្ជមានចំពោះការផ្លាស់ប្តូរជាបន្តបន្ទាប់ក្នុងការថែទាំព្យាបាល និងវិជ្ជាជីវៈរបស់អ្នក ។ ការអភិវឌ្ឍវិជ្ជាជីវៈបន្តធ្វើឱ្យអ្នកតាមទាន់នូវបច្ចុប្បន្នភាពហើយ «មានសម្បទាគ្រប់គ្រាន់» ក្នុងការប្រកបវិជ្ជាជីវៈ និងរក្សាបាននូវនិយាមវិជ្ជាជីវៈដែលចាំបាច់សម្រាប់វិជ្ជាជីវៈថែទាំរបស់អ្នក ។ វាក៏មានអត្ថប្រយោជន៍សម្រាប់ការអភិវឌ្ឍ និងភាពរីកចម្រើនលើអាជីពក៏ដូចជាការពេញចិត្តលើការងាររបស់អ្នកផងដែរ។

៤. តើការប្រកបវិជ្ជាជីវៈមានន័យយ៉ាងដូម្តេច?

ការប្រកបវិជ្ជាជីវៈ ក្នុងបរិបទនេះសំដៅដល់ រាល់តួនាទីដែលបុគ្គលម្នាក់ៗប្រើជំនាញនិងចំណេះដឹងជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ក្នុងវិជ្ជាជីវៈរបស់ពួកគេ។

ការប្រកបវិជ្ជាជីវៈ មិនសំដៅតែការផ្តល់សេវាព្យាបាល ថែទាំវេជ្ជសាស្ត្រ ជាមួយអតិថិជនដោយផ្ទាល់នោះទេ ដោយរាប់បញ្ចូលទាំងការងារគ្រប់គ្រងរដ្ឋបាល អប់រំ/បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់ប្រឹក្សា អភិវឌ្ឍគោលនយោបាយ ឬ បទប្បញ្ញត្តិ និងតួនាទីផ្សេងៗទៀត ដែលប៉ះពាល់ដល់សុវត្ថិភាព ប្រសិទ្ធភាពនៃការផ្តល់សេវាតាមរយៈវិជ្ជាជីវៈនោះ ទោះជាបានឬមិនបានទទួលកម្រៃក៏ដោយ ។

អ្នកប្រកបវិជ្ជាជីវៈថែទាំ សំដៅដល់អ្នកវិជ្ជាជីវៈថែទាំ ដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ។

៥. តើខ្ញុំពណ៌នាអំពីបរិបទនៃការប្រកបវិជ្ជាជីវៈរបស់ខ្ញុំយ៉ាងដូចម្តេច?

បរិបទនៃការប្រកបវិជ្ជាជីវៈសំដៅលើឱកាសដែលកំណត់នូវការប្រកបវិជ្ជាជីវៈរបស់បុគ្គលម្នាក់។ ឱកាសទាំងនេះរួមមាន ៖

- ប្រភេទនៃការប្រកបវិជ្ជាជីវៈ (ឧ. ការផ្តល់សេវាសុខាភិបាល ការគ្រប់គ្រង រដ្ឋបាល ការអប់រំបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ)
- ទីតាំងនៃការប្រកបវិជ្ជាជីវៈ (ឧ. ទីប្រជុំជន តំបន់ជនបទ តំបន់ដាច់ស្រយាល)
- លក្ខណៈនៃអ្នកជំងឺ ឬអតិថិជន (ឧ. ស្ថានភាពសុខភាព អាយុ តម្រូវការការសិក្សារៀនសូត្រ)
- ការយកចិត្តទុកដាក់លើការប្រកបវិជ្ជាជីវៈ (ឧ. ការលើកកម្ពស់សុខភាព ការសិក្សាស្រាវជ្រាវ ការគ្រប់គ្រងការបង្រៀន)
- កម្រិតដែលការប្រកបវិជ្ជាជីវៈមានស្វ័យភាព
- ធនធានដែលមាន រួមទាំងទំនាក់ទំនងជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត

៦. តើខ្ញុំត្រូវបំពេញពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តប៉ុន្មានពិន្ទុ?

នៅពេលដែលអ្នកទទួលអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំដំបូង គណៈគិលានុបដ្ឋាកកម្ពុជា តម្រូវឱ្យអ្នកបំពេញចំនួនពិន្ទុសរុប ៦០ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អំឡុងពេលវដ្តរយៈពេល ៣ ឆ្នាំ ។

អ្នកប្រកវិជ្ជាជីវៈថែទាំដែលជាជនបរទេស តម្រូវឱ្យបំពេញពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្តអប្បបរមា ២០ពិន្ទុ ក្នុងវដ្ត ១ ឆ្នាំ ។

១ ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត គឺស្មើនឹង១ម៉ោងនៃការរៀនសកម្ម មានន័យថា៦០ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងរយៈពេល ៣ ឆ្នាំ ស្មើនឹង ៦០ ម៉ោងនៃរៀនសកម្ម។

ការរៀនសកម្ម គឺជាចំនួនម៉ោងជាក់ស្តែងដែលអ្នកប្រកបវិជ្ជាជីវៈថែទាំ ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសិក្សា ដើម្បីរក្សានូវសមត្ថភាព និងអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគាត់ ។ ពិន្ទុសម្រាប់សកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈបន្តនីមួយៗ អាស្រ័យលើចំនួនម៉ោងជាក់ស្តែងដែលអ្នកប្រកបវិជ្ជាជីវៈថែទាំ ចូលរួមយ៉ាងសកម្មនៅក្នុង

សកម្មភាពសិក្សា ។ ពេលវេលាចំណាយសម្រាប់សកម្មភាពកម្មវិធីដូចជា ការចុះឈ្មោះ ការសម្រាកពិសារអាហារសម្រន់ សុន្ទរកថានិងកម្មវិធីផ្សេងៗ មិនត្រូវបានទទួលស្គាល់ថាជាការរៀនសកម្ម និងមិនអាចចាត់ចូល ជាពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តបានទេ ។

៧. ខ្ញុំធ្វើការក្រៅម៉ោង តើខ្ញុំចាំបាច់ត្រូវបំពេញ ៦០ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្នុងរយៈពេល ៣ ឆ្នាំ នៃវដ្ត ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែរឬទេ?

អ្នកត្រូវបានតម្រូវឱ្យបំពេញ ៦០ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្នុងវដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត រយៈពេល ៣ ឆ្នាំ ដើម្បីរក្សាអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំរបស់អ្នក ។ លក្ខខណ្ឌតម្រូវនេះមិនគិតពីចំនួនម៉ោងដែលអ្នកបំពេញការងារនោះទេ។

៨. តើខ្ញុំត្រូវធ្វើផែនការ ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្ញុំដោយរបៀបណា?

គណៈគិលានុបដ្ឋាកកម្ពុជាបានបង្កើតទម្រង់ផែនការសិក្សាផ្ទាល់ខ្លួនសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (សូមមើលឧបសម្ព័ន្ធ ក) ដែលអ្នកអាចប្រើប្រាស់ក្នុងការកំណត់នូវគោលដៅនៃការសិក្សាវិជ្ជាជីវៈរបស់អ្នកផ្ទាល់សម្រាប់វដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ អ្នកក៏អាចជ្រើសរើសផែនការសិក្សាផ្ទាល់ខ្លួនរបស់អ្នកបានដែរ។ អ្នកត្រូវធានាថា ផែនការសិក្សាផ្ទាល់ខ្លួនដែលអ្នកបានជ្រើសរើសសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវបានដោះស្រាយគ្រប់ព័ត៌មានដែលបានកំណត់នៅក្នុងផែនការសិក្សាផ្ទាល់ខ្លួនសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់គណៈគិលានុបដ្ឋាកកម្ពុជា។

គោលបំណងនៃការធ្វើផែនការគឺដើម្បីឱ្យអ្នកអាចកំណត់គោលដៅនៃការរៀនរយៈពេលខ្លី ឬរយៈពេលវែង ដែលកំណត់សកម្មភាពពាក់ព័ន្ធ ដើម្បីសម្រេចបានគោលដៅ និងតាមដានវឌ្ឍនភាពក្នុងការសម្រេចគោលដៅរបស់អ្នក ។ វាធានាថាអ្នកអាចបំពេញនូវពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្នុងវដ្តរយៈពេល ៣ ឆ្នាំ និងមានសិទ្ធិបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ ។

៩. តើប្រភេទសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្វីខ្លះ ដែលខ្ញុំអាចចូលរួមបាន?

គណៈគិលានុបដ្ឋាកកម្ពុជា តម្រូវឱ្យអ្នកប្រកបវិជ្ជាជីវៈថែទាំម្នាក់ៗចូលរួមសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តផ្សេងៗ ដែល៖ (១) ពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈបច្ចុប្បន្ន និងអនាគត និង (២) ឆ្លើយតបទៅនឹងតម្រូវការសិក្សាដែលបានកំណត់ ។ សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងនេះ ត្រូវបានគេរំពឹងថានឹង ពង្រីកចំណេះដឹង វិជ្ជាជីវៈ ដែលមានស្រាប់ និងមិនមែនជាផ្នែកនៃតម្រូវការការងារប្រចាំថ្ងៃឡើយ។

អ្នកអាចជ្រើសរើសសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តនានា ក្នុងប្រទេសកម្ពុជា ឬក្រៅប្រទេស ។ ការចូលរួមសន្និសីទ អន្តរជាតិ ឬថ្នាក់ក្រោយឧត្តមសិក្សាពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈថែទាំភាគច្រើនជាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តនៅក្រៅប្រទេស។

តារាង ១ ខាងក្រោម គឺជាបញ្ជីនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានបញ្ចូលនូវ ចំនួនពិន្ទុ និងពិន្ទុអតិបរមា នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែងដែលផ្តល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា។ ប្រសិនបើសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលអ្នកកំពុងតែធ្វើការពិចារណាមិនមានកំណត់ក្នុងបញ្ជីខាងក្រោម អ្នកអាចសួរមកគណៈគិលានុបដ្ឋាកកម្ពុជាថ្នាក់ជាតិ តាមរយៈអ៊ីម៉ែល៖unsan888@gmail.com ដើម្បីជានាថាសកម្មភាពនោះនឹងត្រូវបានទទួលស្គាល់សម្រាប់រាប់បញ្ចូលជាពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

តារាងទី១. សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការផ្តល់ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ល.រ	សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត	ចំនួនពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត (១ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត= ១ ម៉ោង នៃការរៀនសកម្ម)	ចំនួនពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អតិបរមា
១	ការពិភាក្សាករណីសិក្សាជាក្រុម/ ចូលរួមការប្រជុំបច្ចេកទេស (កូឡូក)	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀន សកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
២	ការសិក្សាដោយខ្លួនឯង* (អានអត្ថបទទិនានុប្បវត្តិ នៅក្នុងទិនានុប្បវត្តិល្បីៗទាក់ទងនឹងសុខភាព ឬការបោះពុម្ពផ្សាយ តាមអ៊ីនធឺណិតទាក់ទងនឹងសុខភាព ឬ វេប៊ីណា (**Webinars**) ឬ វីដេអូទាក់ទងនឹងសុខភាព) * ត្រូវការកសម្គតាងជាលាយលក្ខណ៍អក្សរ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀន សកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ ពិន្ទុ
៣	សិក្ខាសាលាបណ្តុះបណ្តាល ដែលមានរយៈពេល ១ថ្ងៃ - ២សប្តាហ៍	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១៥ពិន្ទុ
៤	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល > ២សប្តាហ៍ ទៅ ៣ខែ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២៥ពិន្ទុ
៥	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល > ៣ខែ ទៅ ៦ខែ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ៣៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ៣៥ពិន្ទុ
៦	បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល >៦ ទៅ ១២ខែ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ រហូតដល់អតិបរមា ៤៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ៤៥ពិន្ទុ

៧	ចូលរួមការអប់រំនៅកន្លែងធ្វើការ វគ្គសិក្សាក្នុងពេលបំពេញការងារ(**In-service training**) ឬ កម្មវិធីអភិវឌ្ឍជំនាញ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម នីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
៨	ចូលរួមសន្និសីទក្នុងប្រទេសកម្ពុជា	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀន សកម្មនីមួយៗ	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង
៩	ចូលរួមសន្និសីទ សន្និបាត មហាសន្និបាត ក្រៅប្រទេស	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២០ពិន្ទុ
១០	ស្រាវជ្រាវ រៀបចំ សម្រាប់ធ្វើបទបង្ហាញ នៅម៉ោងបង្រៀន ឬបទបង្ហាញក្នុងសន្និសីទជាតិ ឬអន្តរជាតិ (ដែលមិនមែនជាផ្នែកនៃការបង្រៀនដូចធម្មតា)	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងស្រាវជ្រាវ រៀបចំ ដើម្បីធ្វើបទបង្ហាញ រហូតដល់ អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១១	ចូលរួមជាសមាជិកក្នុងក្រុមស្រាវជ្រាវ ឬ ការងារគម្រោងទាក់ទងនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១២	ចូលរួមជាសមាជិកក្នុងក្រុមក្នុងការ បង្កើតគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំ នានាទាក់ទងនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១៣	ស្រាវជ្រាវបន្ថែមនិងរៀបចំ ដើម្បីអភិវឌ្ឍ តួនាទីជាគ្រូណែនាំតាមមន្ទីរពេទ្យ គ្រូណែនាំ គ្រូបង្វឹកបុគ្គលិកឬនិស្សិត ហើយមានផែនការបណ្តុះបណ្តាលដែលមានឯកសារត្រឹមត្រូវ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១០ពិន្ទុ
១៤	ចូលរួមពិនិត្យនិងកែសម្រួលឯកសារអប់រំពាក់ព័ន្ធនឹងសុខាភិបាល អត្ថបទទិនានុប្បវត្តិ ជំពូកក្នុងសៀវភៅ ឬ ឯកសារសិក្សាស្រាវជ្រាវ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១៥ពិន្ទុ
១៥	ក្នុងនាមជាសហនិពន្ធ ចុះផ្សាយឯកសារ ឬរបាយការណ៍ ពាក់ព័ន្ធនឹងសុខាភិបាល	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ១៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ១៥ពិន្ទុ
១៦	សរសេរអត្ថបទស្រាវជ្រាវ ជំពូកសៀវភៅ ឬរបាយការណ៍ក្នុងនាមជាអ្នកនិពន្ធទី១ ហើយបញ្ជូនដើម្បីចុះផ្សាយ	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២០ពិន្ទុ
១៧	ចុះផ្សាយឯកសារ ជំពូកសៀវភៅ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខាភិបាល ក្នុងនាមជាអ្នកនិពន្ធទី១	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២០ពិន្ទុ

១៨	ជាប្រធានដឹកនាំក្នុងការ សិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២៥ពិន្ទុ
១៩	ជាប្រធានសម្របសម្រួលក្នុង ការធ្វើគម្រោងទាក់ទងនឹងសុខភាព	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ២៥ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ២៥ពិន្ទុ
២០	រៀនវគ្គក្រោយឧត្តមសិក្សាដែលពាក់ព័ន្ធ នឹងជំនាញ នៅក្នុងប្រទេស ឬក្រៅប្រទេស ដែល ទទួលបានគុណវុឌ្ឍិជាផ្លូវការ ដូចជា បរិញ្ញាបត្រ សញ្ញាបត្រ បរិញ្ញាបត្រជាន់ ខ្ពស់ ឬ បណ្ឌិត	១ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា ៦០ម៉ោង	ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាក់ស្តែង រហូតដល់អតិបរមា ៦០ពិន្ទុ

១០. តើប្រភេទនៃការផ្តល់សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត បែបណាដែលត្រូវបានទទួលស្គាល់សម្រាប់សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្ញុំ?

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត នឹងត្រូវអនុវត្តជាចម្បងតាមរយៈ៖

- ការសិក្សាជាមួយគ្រូ ឬ អ្នកសម្របសម្រួលដោយផ្ទាល់ ឬការរៀនដោយខ្លួនឯង
- ការរៀន និងការបណ្តុះបណ្តាលពីចម្ងាយ(Online training)និងការសិក្សាជាក្រុម ដោយការធ្វើបទបង្ហាញតាមវីដេអូ

ចំពោះសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតាមរយៈការបណ្តុះបណ្តាលពីចម្ងាយ(Online training) ចាំបាច់ត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីសកម្មភាព (វិញ្ញាបនបត្របញ្ចប់ការសិក្សា និងការវាយតម្លៃ)។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតាមរយៈការបណ្តុះបណ្តាលពីចម្ងាយ(Online training) ដែលជាលក្ខណៈអន្តរជាតិអាចត្រូវបានទទួលស្គាល់ដោយគណៈគិលានុបដ្ឋាកកម្ពុជា នៅពេលដែលការបណ្តុះបណ្តាលទាំងនោះបានរៀបចំឡើងដោយអ្នកផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលមានកេរ្តិ៍ឈ្មោះ និងរួមបញ្ចូលការវាយតម្លៃជាឯកសារ

១១. តើសកម្មភាពអ្វីខ្លះ ដែលមិនមានលក្ខណៈសម្បត្តិជាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត?

ឧទាហរណ៍ខាងក្រោមជាសកម្មភាពដែលមិនមានលក្ខណៈសម្បត្តិជាការអភិវឌ្ឍវិជ្ជាជីវៈបន្ត៖

- សកម្មភាពជាប្រចាំនៅសាលា
- ការសរសេរលើកិច្ចការងារ
- ការចងក្រងសៀវភៅនិស្សិតសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង
- កិច្ចប្រជុំជាមួយបុគ្គលិក និង/ឬកិច្ចប្រជុំការងារដ្ឋបាល

- ទស្សនកិច្ច និង/ឬការទស្សនានៃការតាំងពិពណ៌ និងការបង្ហាញអំពីបច្ចេកវិទ្យា
- សមាជិកភាពនៃស្ថាប័នវិជ្ជាជីវៈ ក្រុមប្រឹក្សាវិជ្ជាជីវៈ ឬសមាគម
- កិច្ចប្រជុំដែលរៀបចំដោយក្រុមហ៊ុនឱសថ ឬអ្នកនាំចូលផលិតផល និងឧបករណ៍បច្ចេកទេស (រួមមាន (បច្ចេកវិទ្យាឧបករណ៍ជំនួយ) ឬអ្នកតំណាងសម្រាប់គោលបំណងទីផ្សារ និង/ឬការផ្សព្វផ្សាយ ផលិតផលរបស់ពួកគេ។

១២. តើខ្ញុំអាចចូលរួមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្រៅពីជំនាញប្រកបវិជ្ជាជីវៈថែទាំរបស់ខ្ញុំបានដែរឬទេ?

ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់អ្នកអាចរាប់បញ្ចូលសកម្មភាពនានា ពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈថែទាំរបស់អ្នក ក្រៅពីការងារដែលអ្នកអនុវត្តរាល់ថ្ងៃបាន។ អ្នកប្រកបវិជ្ជាជីវៈថែទាំ គឺត្រូវបានលើកទឹកចិត្ត ឱ្យចូលរួមសកម្មភាព ឆ្លុះបញ្ចាំងលើការប្រកបការងាររបស់ពួកគេ និងកំណត់ចំណេះដឹងដែលពួកគេ អាចទទួលបានអត្ថប្រយោជន៍ជា អតិបរិមាពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលពួកគេបានជ្រើសរើស ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ គឺជាឱកាសសំខាន់ក្នុងការរៀនសូត្រ ដែលរួមមានដូចជា៖

- ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- ជំងឺឆ្លង
- ជំងឺមិនឆ្លង
- ការស្រាវជ្រាវពាក់ព័ន្ធនឹងសុខាភិបាល
- សុខភាពបន្តពូជ
- សុខភាពមាតា និងទារក
- បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT)
- សុវត្ថិភាព និងសុខភាពការងារ
- ការគ្រប់គ្រងគ្រោះមហន្តរាយ
- ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ
- ការគ្រប់គ្រងគុណភាពសេវាសុខាភិបាល
- ការរៀននិងការបង្រៀន

១៣. តើមានវគ្គបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬ អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាល ការអភិវឌ្ឍ វិជ្ជាជីវៈបន្តណាខ្លះដែលគណៈគិលានុបដ្ឋាកកម្ពុជា*ទទួលស្គាល់*?

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលពាក់ព័ន្ធនឹងវគ្គបណ្តុះបណ្តាលមានរយៈពេលមួយថ្ងៃ ឬលើស ត្រូវ មានឯកសារដែលបង្ហាញពី គោលបំណង និងគោលដៅ ជាមួយអ្នកជំនាញ អ្នកសម្របសម្រួល ឬ/និង អ្នកធ្វើបទ បង្ហាញ ឬ/និងដោយរួមបញ្ចូលការវាយតម្លៃដែលបង្ហាញពីការអនុវត្តនូវចំណេះដឹង និងជំនាញថ្មីៗ នៅក្នុងការ ប្រកបវិជ្ជាជីវៈថែទាំ។

គណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្នុងការផ្តល់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាច្រើនដល់អ្នកវិជ្ជាជីវៈថែទាំ អ្នកប្រកបវិជ្ជាជីវៈថែទាំ។ ស្ថាប័នទាំងនោះរួមមាន៖

- ក្រសួងសុខាភិបាល (MoH)
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគៈ បាត់ដំបង ស្ទឹងត្រែង កំពង់ចាម និងកំពត
- វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ
- សាកលវិទ្យាល័យ ឯកជនដែលផ្តល់ការអប់រំផ្នែកសុខាភិបាល-ហើយត្រូវបានអនុញ្ញាតដោយក្រសួងអប់រំយុវជននិងកីឡា (MOEYS) និងក្រសួងសុខាភិបាល
- មន្ទីរពេទ្យរដ្ឋ និងឯកជន
- មន្ទីរសុខាភិបាលខេត្ត
- មន្ទីរពេទ្យបង្អែកខេត្ត
- សមាគមវិជ្ជាជីវៈសុខាភិបាល

ប្រសិនបើអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត មិនមាននៅក្នុងការបរិយាយខាងលើ ពួកគេត្រូវតែធ្វើការជាដៃគូជាមួយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈគិលានុបដ្ឋាកកម្ពុជាទទួលស្គាល់ ឬធ្វើការស្នើសុំទៅគណៈគិលានុបដ្ឋាកកម្ពុជាដើម្បីទទួលស្គាល់ថាជាអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

គណៈគិលានុបដ្ឋាកកម្ពុជានឹងមិនទទួលស្គាល់នូវគ្រប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តដែលបានរៀបចំឡើងដោយក្រុមហ៊ុនឱសថ ឬក្រុមហ៊ុនពាណិជ្ជកម្មតែឯងឡើយ។

***អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងអស់ ត្រូវតែផ្តល់ឯកសារពាក់ព័ន្ធដែលតម្រូវដោយគណៈគិលានុបដ្ឋាកកម្ពុជាជាមុន ដើម្បីស្នើសុំពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

១៤. តើខ្ញុំគណនាម៉ោងនៃការរៀនសកម្ម សម្រាប់ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្ញុំដោយរបៀបណា?

ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តនីមួយៗ គឺអាស្រ័យលើចំនួនម៉ោងជាក់ស្តែងដែលអ្នកប្រកបវិជ្ជាជីវៈថែទាំ ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសិក្សា។ ពេលវេលាចំណាយសម្រាប់សកម្មភាពកម្មវិធីដូចជា ការចុះឈ្មោះ ការសម្រាកពិសារអាហារសម្រន់ សុន្ទរកថានិងកម្មវិធីផ្សេងៗ មិនត្រូវបានទទួលស្គាល់ថាជាការរៀនសកម្ម និងមិនអាចចាត់ចូលជាពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តបានទេ ។

ឧទាហរណ៍៖ សិក្ខាសាលាដែលមានរយៈពេល ១ ថ្ងៃ ដែលក្នុងនោះរាប់បញ្ចូលទាំង ២ ម៉ោងនៃការពិសារអាហារ សម្រាកអាហារសម្រន់ និង ១ម៉ោងសម្រាប់សុន្ទរកថា នោះបានន័យថា សកម្មភាពរៀនសកម្មមានតែ ៥ ម៉ោងប៉ុណ្ណោះ ហើយក៏បានន័យថា ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសរុបសម្រាប់សិក្ខាសាលានេះ គឺ ៥ ពិន្ទុ ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តខ្លះ ដែលមាននៅក្នុងតារាងនៅសំណួរទី ៩ រួមបញ្ចូលចំនួនអតិបរមានៃពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានផ្តល់ឱ្យ ដែលមិនគិតពីចំនួនម៉ោងសរុបនៃការរៀនសូត្រសកម្ម ។
ឧទាហរណ៍៖ វគ្គបណ្តុះបណ្តាលរយៈពេល ៤ ថ្ងៃ ដែលមានការរៀនសូត្រសកម្មសរុប អាចដល់២៤ ម៉ោងស្មើនឹង ២៤ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ទោះយ៉ាងនេះក្តី ពិន្ទុអតិបរមានៃពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដែលមានរយៈពេលពី ១ ថ្ងៃ ទៅ ២សប្តាហ៍ គឺ ១៥ ពិន្ទុនៃការអភិវឌ្ឍ វិជ្ជាជីវៈបន្ត។ ដូច្នេះវគ្គបណ្តុះបណ្តាលរយៈពេល ៤ ថ្ងៃនឹងត្រូវបានគេឱ្យពិន្ទុចំនួនអតិបរមា១៥ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

១៥. អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តនៅក្រៅប្រទេស អាចផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាពិន្ទុ តើខ្ញុំយកមកគិតម៉ោងតាមរបៀបណា?

អ្នកប្រកបវិជ្ជាជីវៈថៃទាំ អាចពិភាក្សាជាមួយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្នុងការបញ្ជាក់ម៉ោងដែលស្មើគ្នា សម្រាប់ពិន្ទុដែលពួកគាត់បានទទួល ។ អ្នកត្រូវចងចាំថាម៉ោងដែលបានគណនាសម្រាប់សកម្មភាពនីមួយៗ គឺផ្អែកលើចំនួនម៉ោងសរុប ដែលអ្នកប្រកបវិជ្ជាជីវៈថៃទាំបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀន ។ មានន័យថា ម៉ោងសម្រាប់សកម្មភាព ចុះឈ្មោះ សម្រាកពិសារអាហារ សុន្ទរកថា និងពិធីបើក មិនអាចយកគណនាថាជាម៉ោងនៃ**ការអភិវឌ្ឍវិជ្ជាជីវៈបន្ត**បានឡើយ ។

១៦. មានអ្វីកើតឡើងប្រសិនបើពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សរុបរបស់ខ្ញុំលើសក្នុងរយៈពេល៣ ឆ្នាំនៃវដ្តការអភិវឌ្ឍវិជ្ជាជីវៈបន្ត?

សម្រាប់ឆ្នាំនីមួយៗនៃវដ្ត ការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកវិជ្ជាជីវៈថៃទាំដែលមានសញ្ជាតិខ្មែរ តម្រូវឱ្យបំពេញពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្តអប្បបរមា ១៥ ពិន្ទុរៀងរាល់ឆ្នាំ ។

អ្នកប្រកវិជ្ជាជីវៈថៃទាំដែលជាជនបរទេស តម្រូវឱ្យបំពេញពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អប្បបរមា ២០ ពិន្ទុក្នុងវដ្ត ១ឆ្នាំ ។

អ្នកអាចសន្សំពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ឱ្យបានច្រើនជាងចំនួនពិន្ទុ ដែលតម្រូវដោយគណៈគិលានុបដ្ឋាកកម្ពុជា ។ពិន្ទុសរុបលើសក្នុងវដ្តមួយមិនអាចផ្ទេរ ទៅវដ្តបន្ទាប់បានទេ ។

១៧. តើខ្ញុំកត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់ខ្ញុំតាមរបៀបណា?

អ្នកអាចជ្រើសរើសកត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់អ្នក តាមមធ្យោបាយដែលល្អបំផុតសម្រាប់ខ្លួនឯង និងបំពេញតាមលក្ខខណ្ឌរបស់គណៈគិលានុបដ្ឋាកកម្ពុជាសម្រាប់ឯកសារជាកស្តតាង នៃការចូលរួម

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ។ ឧបសម្ព័ន្ធ ខ ដែលមានឈ្មោះថា “កំណត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត” ផ្តល់ជាឧទាហរណ៍ស្តីពីព័ត៌មាន ដែលគណៈគិលានុបដ្ឋាកកម្មជាត្រូវការ អំពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់អ្នក សម្រាប់ការដាក់ពាក្យសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ។ គំរូនេះគឺស្រដៀងគ្នាទៅនឹង ទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណឡើងវិញ តាមប្រព័ន្ធអនឡាញហើយគំរូនេះ ត្រូវភ្ជាប់ជាមួយផែនការការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់អ្នក និងឯកសារជាភស្តុតាង សម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តនីមួយៗ ។

១៨. តើកស្តុតាងសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់ខ្ញុំមានទម្រង់អ្វីខ្លះ? (រួមបញ្ចូលទាំងការរៀនដោយខ្លួនឯង)

អ្នកគួររក្សាទុកឯកសារនៃតម្រូវការសិក្សាដែលអ្នកបានកំណត់ ផែនការនៃការរៀនរបស់អ្នក ការចូលរួមរបស់អ្នកក្នុងសកម្មភាពរៀន ការវាយតម្លៃនានា និងលទ្ធផលដែលទទួលបាន ។ ឯកសារទាំងអស់នេះនឹង ក្លាយជាភស្តុតាងនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាពិសេសការសិក្សាដោយខ្លួនឯង ដែលតម្រូវឱ្យអ្នកផ្តល់ទៅគណៈគិលានុបដ្ឋាកកម្មជា។

រាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់សកម្មភាពរៀនដោយខ្លួនឯងត្រូវការឯកសារយោងជាក់លាក់ពីអ្នកប្រកបវិជ្ជាជីវៈថែទាំ ដែលកំណត់ច្បាស់លាស់៖

(១) គោលបំណងនៃសកម្មភាពនេះ

(២) តម្រូវការរៀនសូត្ររបស់បុគ្គល និងផែនការការអភិវឌ្ឍវិជ្ជាជីវៈបន្តផ្ទាល់ខ្លួន

(៣) សកម្មភាពដែលបានចូលរួម

(៤) ពេលវេលាដែលអ្នកបានចូលរួម

(៥) ការសង្ខេបខ្លីពីលទ្ធផលនៃការរៀន ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តដែលពាក់ព័ន្ធនឹងវគ្គបណ្តុះបណ្តាលមានរយៈពេលមួយថ្ងៃ ឬលើស ត្រូវមានឯកសារដែលបង្ហាញពី គោលបំណង និងគោលដៅ ជាមួយអ្នកជំនាញ អ្នកសម្របសម្រួល ឬ/និង អ្នកធ្វើបទបង្ហាញ ឬ/និងដោយរួមបញ្ចូលការវាយតម្លៃដែលបង្ហាញពីការអនុវត្តនូវចំណេះដឹង និងជំនាញថ្មីៗ នៅក្នុងការប្រកបវិជ្ជាជីវៈថែទាំ។

១៩. តើខ្ញុំត្រូវរក្សាកំណត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់ខ្ញុំរយៈពេលប៉ុន្មាន?

គណៈគិលានុបដ្ឋាកកម្មជាសូមផ្តល់ជាអនុសាសន៍ថា អ្នកត្រូវរក្សាឯកសារជាភស្តុតាងនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់អ្នក រួមទាំងការរៀនដោយខ្លួនឯង ក្នុងរយៈពេលយ៉ាងតិច ៣ ឆ្នាំ។

២០. តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នៃចំនួនម៉ោងនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត?

នៅពេលបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំ អ្នកត្រូវប្រកាស និងផ្តល់ឯកសារភស្តុតាងនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់អ្នក។ ដោយអនុលោមតាមគោលការណ៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកបវិជ្ជាជីវៈថែទាំត្រូវបំពេញឱ្យបាន៦០ (ហុកសិប)ពិន្ទុនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងរដ្ឋ៣ឆ្នាំ។

អ្នកប្រកបវិជ្ជាជីវៈថែទាំទាំងអស់ត្រូវស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈយ៉ាងតិច ៣) បី(ខែ មុនពេលអាជ្ញាបណ្ណអស់សុពលភាព។ នៅពេលស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ អ្នកប្រកបវិជ្ជាជីវៈថែទាំត្រូវប្រកាសនិងផ្តល់ឯកសារភ័ស្តុតាងដែលបង្ហាញថាសាមីខ្លួនបានអនុវត្តតាមនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ក្នុងករណីដែលអ្នកប្រកបវិជ្ជាជីវៈថែទាំមិនបានបំពេញពិន្ទុគ្រប់ចំនួនតាមលក្ខខណ្ឌគណៈគិលានុបដ្ឋាកកម្ពុជា នឹងមិនបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈថែទាំជូនឡើយ។

២១. តើគណៈគិលានុបដ្ឋាកកម្ពុជាធ្វើសវនកម្មចំពោះគ្រប់អ្នកប្រកបវិជ្ជាជីវៈថែទាំដែរឬទេ?

ការអនុលោមតាមនិយាម និងគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត គណៈគិលានុបដ្ឋាកកម្ពុជាអាចធ្វើសវនកម្ម បានគ្រប់ពេល ឬ នៅពេលទទួលបានបណ្តឹងដែលពាក់ព័ន្ធនឹងសម្បទា ឬកំហុសឆ្គងក្នុងការប្រកបវិជ្ជាជីវៈថែទាំ ។

អ្នកនឹងតម្រូវឱ្យបង្ហាញភស្តុតាង ដែលអ្នកបានបំពេញតាមលក្ខខណ្ឌ និងផ្តល់នូវឯកសារថតចម្លងនៃផែនការ ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់អ្នក សម្រាប់រដ្ឋនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត រយៈពេល៣ ឆ្នាំ។

សម្រាប់ព័ត៌មានបន្ថែមសូមពិនិត្យមើលឯកសារខាងក្រោម៖

- និយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំ (ខែវិច្ឆិកា ឆ្នាំ២០១៩)
- គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (ខែវិច្ឆិកា ២០១៩)
- គោលការណ៍សម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (ខែវិច្ឆិកា ឆ្នាំ២០១៩)

សូមចូលទៅកាន់ គេហទំព័រ គណៈគិលានុបដ្ឋាកកម្ពុជា(http://cambodiancouncilofnurse.com/kh/)